Food and Agriculture Organization of the United Nations

This programme is co-funded by the European Union




# របាយការណ៍ស្ថិតិផលនេសាទសមុទ្រ ប្រចាំឆ្នាំ២០២២

ចងក្រងដោយ៖ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ

*ការបោះពុម្ពផ្សាយនេះទទួលបានការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។ ខ្លឹមសារនៃការបោះផ្សាយនេះជាការទទួលខុសត្រូវរបស់រដ្ឋបាលជលផល ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។*

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្ថិតិប្រចាំឆ្នាំនេះ ត្រូវបានរៀបចំឡើងដោយមានជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប ក្រោមកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន ដោយមានជំនួយបច្ចេកទេសពីអង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ដែលបានការសហការយ៉ាងជិតស្និទ្ធជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ។ សូមថ្លែងអំណរគុណជាពិសេសចំពោះ **លោក ស៊ុយ សេរីវឌ្ឍន៍** ប្រធានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ និងមន្ត្រីនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ ដែលបានផ្តល់ការណែនាំទូទៅ និងមតិយោបល់លើសេចក្តីព្រាងចុងក្រោយ និង**លោក លី គន្ធី** ដែលបានរៀបចំនិងវិភាគទិន្នន័យស្ថិតិប្រចាំខែសម្រាប់ជាមូលដ្ឋានសម្រាប់របាយការណ៍ប្រចាំឆ្នាំនេះ។ ការវិភាគទិន្នន័យនេះមានការគាំទ្រផ្នែកបច្ចេកទេសពី **លោក Theo Visser** (មន្ត្រីគ្រប់គ្រងជលផលទឹកសាបនៃអង្គការ FAO) និង **លោក សូ ដាណេ** (អ្នកឯកទេសមូលដ្ឋានទិន្នន័យនៃអង្គការ FAO) និង**លោក អ៊ុន បូរិន** (អ្នកឯកទេសស្រាវជ្រាវជលផលនៃអង្គការ FAO)។

## ចងក្រងដោយ

**លោក ស៊ុយ សេរីវឌ្ឍន៍** និង**លោក លី គន្ធី**

ដោយមានជំនួយបច្ចេកទេសពីគម្រោង FAO CAPFISH

## គុណកថាបង្អែក

រដ្ឋបាលជលផល (២០២២)។ របាយការណ៍ស្ថិតិជលនេសាទសមុទ្រក្នុងប្រទេសកម្ពុជា វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រនៃរដ្ឋបាលជលផល រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៤៥ទំព័រ។

## ទំនាក់ទំនង

រដ្ឋបាលជលផល
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ
អាគារលេខ ១៨៦ មហាវិថីនរោត្តម រាជធានីភ្នំពេញ ប្រទេសកម្ពុជា

© រដ្ឋបាលជលផល
រក្សារសិទ្ធគ្រប់យ៉ាង។ ការបោះពុម្ពឡើងវិញទាំងស្រុង ឬផ្នែកណាមួយសម្រាប់គោលបំណងអប់រំ ឬមិនរកប្រាក់ចំណេញ មិនតម្រូវឱ្យសុំការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិបញ្ញាឡើយ ដោយគ្រាន់តែថ្លែងអំណរគុណដល់ប្រភពដើម។ រាល់ការបោះពុម្ព ការចម្លង ឬចែកចាយសម្រាប់លក់បន្ត ឬគោលបំណងពាណិជ្ជកម្មផ្សេងទៀតត្រូវសុំការអនុញ្ញាតពីរដ្ឋបាលជលផល។
រាល់មតិយោបល់ និងមតិដែលបានបង្ហាញនៅទីនេះ គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនអាចឆ្លុះបញ្ចាំងពីជំហររបស់រដ្ឋបាលជលផល ដៃគូ ឬអង្គការ ដែលផ្តល់មូលនិធិសម្រាប់គម្រោ ងនិងការបោះពុម្ពផ្សាយនោះទេ។

# សេចក្តីសង្ខេប


ការតាមដាន វាយតម្លៃផលនេសាទសមុទ្រតាមបែបវិទ្យាសាស្រ្ត ត្រូវបានអនុវត្ត រយៈពេល៨ខែ ក្នុងឆ្នាំ២០២ ដោយមន្ត្រីនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ រួមសហការពីមន្ត្រីខណ្ឌរដ្ឋបាលជលផលខេត្តតំបន់ឆ្នេរ។ ការអង្កេតផលនេសាទនេះ បានធ្វើឡើងតាមកន្លែងផលនេសាទគោលដៅចំនួន៨ ក្នុងខេត្តតំបន់ឆ្នេរទាំង៤ និងបានធ្វើអង្កេតទូកនេសាទខ្នាតតូចចំនួន៤០៨ និងទូកនេសាទខ្នាតមធ្យមចំនួន១៣៨៣ សរុបទូកចំនួន១៧៩១ ត្រូវបានអង្កេតក្នុងឆ្នាំ២០២២។

តាមកំណត់ត្រាទិន្នន័យផលនេសាទទទួលបាន មិនមានបង្ហាញអំពីការប្រែប្រួលតាមរដូវកាលគួរឱ្យកត់សម្គាល់ បើទោះបីជាមានផលនេសាទកើនខ្ពស់ខ្លាំងនៅខែឧសភានិងខែកក្កដា ក៏ដោយ កត្តានេះបណ្តាលមកពីការឡើងផលនេសាទដោយឧបករណ៍អួនហ៊ុំ និងអួនអូសថ្នាក់មធ្យម។ ការឡើងផលនេសាទដោយទូកអួនអូសបានរួមចំណែកជិត ៦០% នៃផលនេសាទសរុប ដែលបានកត់ត្រា បន្ទាប់មកគឺអួនហ៊ុំ (៨,៧%) និងមងត្រី(៦,២%)។ ការនេសាទដោយឧបករណ៍អួនអូសមាន CPUE ខ្ពស់បំផុតគឺលើសពី ២១០ គ.ក្រ/ថ្ងៃ បន្ទាប់មកទៀតគឺមងត្រីផ្ទោង (១៥១ គ.ក្រ/ថ្ងៃ) និងមងត្រីកាម៉ុង (១០១ គ.ក្រ/ថ្ងៃ)។

សកម្មភាពធ្វើនេសាទស្ថិតក្នុងកម្រិតជាប់លាប់ចន្លោះពី១៧-២១ ថ្ងៃនេសាទ/ខែ។ ករណីដោយឡែក មាននៅខេត្តកែប ដែលទូកនេសាទផ្សេងពីអួនអូសមានសកម្មភាពធ្វើនេសាទទាបជាងគេ និងទូកនេសាទខ្នាតមធ្យម >១៨ ម៉ែត្រ ក្នុងខេត្តកំពត មានសកម្មភាធ្វើនេសាទខ្ពស់ជាងនៅខេត្តផ្សេងទៀត។

ផលនេសាទតាមប្រភេទខ្ពស់បំផុត គឺត្រីកាកឹមខ្លួនខ្លី ដែលតំណាងឱ្យជិត ៣១% នៃផលនេសាទសរុប ខណៈដែលត្រីផ្សេងទៀត (មិនបានបញ្ជាក់ប្រភេទជាក់លាក់ រួមចំណែក១២% និងត្រីជី រួមចំណែក ៨% ក្នុងនោះ បង្គានិងក្តាមរួមចំណែកប្រហែល៤% ក្នុង១ប្រភេទៗ។

ទិន្នន័យ ដែលប្រមូលបានពីការចំណាយប្រតិបត្តិការនេសាទបង្ហាញថា ប្រតិបត្តិការនេសាទស្ទើរតែទាំងអស់នៅក្នុងខេត្តកំពត និងកែប ទទួលបានផលចំណេញ ដោយឡែកនៅខេត្តកោះកុង និងខេត្តព្រះសីហនុ ទិន្នន័យប្រមូលបានបង្ហាញថាមិនទទួលបានប្រាក់ចំណេញ ករណីនេះអាចមកពីការយកទិន្នន័យមិនបានគ្រប់ជ្រុងជ្រោយ។ ជាមួយក្នានេះដែរ ប្រាក់បៀវត្សរ៍ និងថ្លៃប្រេងឥន្ធនៈ គឺជាធាតុផ្សំដ៏ធំបំផុតនៃតម្លៃប្រតិបត្តិការនេសាទ គ្រប់ប្រភេទទូកនេសាទឧបករណ៍ទាំងអស់។

ការវាយតម្លៃផលនេសាទសមុទ្រដែលជាលទ្ធផលបានការកត់ត្រា និងការប៉ាន់ស្មានចំនួនទូកនេសាទចេញទៅនេសាទចំនួន៨០%នោះ ផលនេសាទសរុបសម្រាប់ឆ្នាំ២០២២ មានចំនួន២៣២.៧៥៥ តោន។

របាយការណ៍នេះមានបញ្ចូលអនុសាសន៍មួយចំនួនសម្រាប់ការកែលម្អដល់វិធីសាស្រ្តកត់ត្រាទិន្នន័យ និងការចូលរួមមន្ត្រីខណ្ឌរដ្ឋបាលជលផល និងមន្ត្រីពាក់ព័ន្ធក្នុងការពិនិត្យ និងសុពលភាពទិន្នន័យ ព្រមទាំងចំណុចខ្វះខាតសម្រាប់កែលម្អក្នុងការអនុវត្តក្នុងឆ្នាំ២០២៣។

# តារាងមាតិកា


សេចក្តីថ្លែងអំណរគុណ ..................... i

សេចក្តីសង្ខេប..................... ii

តាមរាងពាក្យបំព្រួញ ..................... iv

១ សេចក្តីផ្តើម និងវិធីសាស្រ្តប្រមូលទិន្នន័យ ..................... ១

២. លទ្ធផលអង្កេត និងតារាងស្ថិតិ ..................... ១

២.១ របាយការណ៍ផលនេសាទ ..................... ២

២.២ របាយការណ៍ផលនេសាទតាមឧបករណ៍..................... ៣

២.៣ កម្លាំងធ្វើនេសាទ ..................... ៩

២.៤ ផលនេសាទនិងតម្លៃតាមប្រភេទ ..................... ១១

២.៥ ការប៉ាន់ប្រមាណផលនេសាទសរុប ..................... ១៤

២.៦. ស្តុកត្រីជាន់គ្នា ការធ្វើចំណាកស្រុក និងឆ្លងដែនស្តុកត្រីខ្ពស់ ..................... ១៨

២.៧ ទិន្នន័យសេដ្ឋកិច្ចសង្គម ..................... ១៩

៣. សេចក្តីសន្និដ្ឋាននិងអនុសាសន៍ ..................... ២០

# តារាងពាក្យបំព្រួញ

| | | |
|---|---|---|
| AP | Aquatic Plants | វារីរុក្ខជាតិ |
| CAPFISH | Cambodia Programme for Sustainable and Inclusive Growth in the Fisheries Sector | កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នៈសមាសភាគការនេសាទ |
| CPUE | Catch per Unit of Effort | ផលចាប់ក្នុងមួយឯកត្តាកម្លាំងនេសាទ |
| EU | European Union | សភាពអឺរ៉ុប |
| FAC | Fishing Activity Coefficient | ការប៉ាន់ប្រមាណអំពីមេគុណ |
| FAO | Food and Agriculture Organisation | អង្គការស្បៀងនិងកសិកម្ម |
| FCMAS | Fish Catch Monitoring Assessment Survey | ការតាមដាន វាយតម្លៃផលនេសាទសមុទ្រតាមបែបវិទ្យាសាស្រ្ត |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| FiAC | Fisheries Administration Cantonment | ខណ្ឌរដ្ឋបាលជលផល |
| GFC | Gross Cash Flow | លំហូរសាច់ប្រាក់សរុប |
| GP% | Gross Profit magin | អត្រាប្រាក់ចំណេញដុល |
| KoBo | | កម្មវិធីប្រមូលទិន្នន័យ កូបូ |
| MaFReDI | Marine Fisheries Research and Development Institute | វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ |
| RPOA | Regional Plan of Action | ផែនការកម្មភាពថ្នាក់តំបន់ |
| SD | Standard Deviation | គម្លាតស្តង់ដារ |
| SEAFDEC | South East Asian Fisheries Development Centre | មជ្ឈមណ្ឌលអភិវឌ្ឍន៍ជលផលអាស៊ីអាគ្នេយ៍ |
| SES | Socio-Economic Survey | ការអង្កេតសេដ្ឋកិច្ច-សង្គម |
| UNCLOS | United Nations Conference on Law of the Sea | សន្និសីទអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ |
| UNFSA | United Nations Fish Stock Agreement | កិច្ចព្រមព្រៀងស្តុកត្រីរបស់អង្គការសហប្រជាជាតិ |
| VMS | Vessel Monitoring System | ប្រព័ន្ធតាមដានទូកនេសាទ |
| ε% | Relative Standard Error | កម្រិតលំអៀងស្តង់ដារ |

# ១ សេចក្តីផ្តើម និងវិធីសាស្រ្តប្រមូលទិន្នន័យ

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលផលសមុទ្រ ដោយមានជំនួយបច្ចេកទេសនៃកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាពនិងបរិយាប័ន្ន នៃអង្គការស្បៀងនិងកសិកម្ម នៃអង្គការសហប្រជាប្រជាជាតិ (FAO CAPFISH) ក្រោមការគាំទ្រថវិការបស់សហភាពអឺរ៉ុប (EU) បាន និងកំពុងអនុវត្តសាកល្បងការតាមដានវាយតម្លៃផលនេសាទសមុទ្រ តាមបែបវិទ្យាសាស្រ្ត នៅតាមកន្លែងឡើងផលនេសាទក្នុងខេត្តទាំងបួនតំបន់ឆ្នេរ។ គោលបំណងនៃការតាមដាន វាយតម្លៃផលនេសាទសមុទ្រនេះ គឺដើម្បីទទួលបានទិន្នន័យឬព័ត៌មានឱ្យកាន់តែប្រសើរអំពីផលនេសាទនិងសមត្ថភាពនៃការធ្វើនេសាទជលផលសមុទ្រនៅប្រទេសកម្ពុជា និងបង្កើតឱ្យមានវិធីសាស្រ្តតាមដាន វាយតម្លៃផលនេសាទសមុទ្រសម្រាប់ខណ្ឌរដ្ឋបាលជលផលអនុវត្តបន្ត ក្រោមការគាំទ្របច្ចេកទេសដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ ដើម្បីធានាបាននូវនិរន្តរភាពនៃការប្រមូលទិន្នន័យផលនេសាទសមុទ្រ។

ការប្រមូលទិន្នន័យត្រូវបានអនុវត្តនៅតាមកន្លែងឡើងផលនេសាទគោលដៅទាំងអស់ ក្នុងខេត្ត ទាំងបួនតាមតំបន់ឆ្នេរ ពីខែឧសភា ដល់ខែធ្នូ ឆ្នាំ២០២២។ ការវិភាគក្នុងរបាយការណ៍នេះផ្តោតចម្បងលើរបាយការណ៍ស្ថិតិប្រចាំខែ ដោយមានបន្ថែមការប៉ាន់ប្រមាណផលនេសាទសរុប ផលនេសាទរាយការណ៍តាមប្រភេទស្ថិតក្រោមអនុសញ្ញាអន្តរជាតិនានា (RPOA និង UNFSA) ទិន្នន័យសេដ្ឋកិច្ច- សង្គម និងការផ្តល់អនុសាសន៍សម្រាប់ធ្វើការកែតម្រូវវិធីសាស្រ្តតាមដាន វាយតម្លៃផលនេសាទសមុទ្រ។ បើមិនមានការបញ្ជាក់អំពីចំនុចផ្សេងគ្នា តារាងទាំងអស់ក្នុងរបាយការណ៍បញ្ចូលទិន្នន័យសង្ខេបតាមត្រីមាស។

ខ្លឹមសារពិស្តារអំពីវិធីសាស្រ្តតាមដានវាយតម្លៃផលនេសាទសមុទ្រ អាចរកបានតាមរយៈឯកសារបោះពុម្ពផ្សាយដោយរដ្ឋបាលជលផល (FiA) ឆ្នាំ២០២១។ ឯកសារណែនាំការតាមដាន វាយតម្លៃផលនេសាទសមុទ្រក្នុងប្រទេសកម្ពុជា ចងក្រងដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រនៃរដ្ឋបាលជលផល រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៣៨ទំព័រ។

# ២. លទ្ធផលអង្កេត និងតារាងស្ថិតិ

ការប្រមូលទិន្នន័យក្នុងកំឡុងឆ្នាំ២០២២ បានបន្តចាប់ពីខែឧសភា ហើយការអង្កេតបានគ្របដណ្តប់លើការឡើងផលនេសាទខ្នាតតូចនិងខ្នាតមធ្យម នៅគ្រប់កន្លែងឡើងផលនេសាទគោលដៅ។ ចំនួនឡើងផលនេសាទខ្នាតតូចមានកម្រិតទាបនៅតាមកន្លែងឡើងផលនេសាទមួយចំនួន គឺអាស្រ័យលើការចាត់ថ្នាក់ទូកអួនអូសជាប្រភេទទូកនេសាទខ្នាតមធ្យម ដោយមិនគិតពីប្រវែងទូក។ សមាមាត្របង្ហាញក្នុងរបាយការណ៍នេះ ឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទូកនេសាទខ្នាតតូចនិងខ្នាតមធ្យម នៅតាមកន្លែងឡើងផលនេសាទគោលដៅ។ ទិន្នន័យ ដែលមាននាពេលបច្ចុប្បន្នត្រូវបានគេប្រើសម្រាប់របាយការណ៍នេះ ល្អបំផុតតាមរយៈការដាក់រួមបញ្ចូលគ្នានៃទិន្នន័យតាមថ្នាក់ទូកនេសាទសម្រាប់ជលផលសមុទ្រទាំងមូល។ ភាពត្រឹមត្រូវតាមបែបស្ថិតិសម្រាប់ការប៉ាន់ប្រមាណលើ CPUE ធ្វើការគណនាដោយដាក់រួមបញ្ចូលគ្នានៃថ្នាក់ទូកនេសាទ-ឧបករណ៍តាមខេត្តនីមួយៗ មានបង្ហាញលម្អិតបន្ថែមទៀតក្នុងតារាងទី២។

**តារាងទី១**. ចំនួនកន្លែងឡើងផលនេសាទ ដែលបានជ្រើសរើសដោយចៃដន្យ កត់ត្រាតាមលំដាប់ទូកនេសាទ និងកន្លែងឡើងផលនេសាទ

| **ខេត្ត** | **កន្លែងឡើងផលនេសាទ** | **ឧសភា-មិថុនា** | | **កក្កដា-កញ្ញា** | | **តុលា-ធ្នូ** | | **ប្រចាំឆ្នាំ** | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ខ្នាតតូច | ខ្នាតមធ្យម | ខ្នាតតូច | ខ្នាតមធ្យម | ខ្នាតតូច | ខ្នាតមធ្យម | ខ្នាតតូច | ខ្នាតមធ្យម | %ខ្នាតតូច |
| កោះកុង | លីយ៉ុងផាត់ | ៨ | ៤៨ | ៩ | ៧៥ | ២១ | ៦២ | ៣៨ | ១៨៥ | ១៧,០% |
| | ថ្មស | ៣១ | ២៥ | ៤០ | ៤៤ | ៤៥ | ៣៩ | ១១៦ | ១០៨ | ៥១,៨% |
| ព្រះសីហនុ | ស្ទឹងហាវ | | ៥៦ | | ៨៣ | ១ | ៨៣ | ១ | ២២២ | ០,៤% |
| | ទំនប់រលក | ១ | ៥៥ | ៥ | ៧៩ | ១៦ | ៦៨ | ២២ | ២០២ | ៩,៨% |
| កំពត | កំពង់កណ្តាល | ២ | ៥៤ | ២ | ៨២ | ៦ | ៧៨ | ១០ | ២១៤ | ៤,៥% |
| | ត្រពាំងរពៅ | ៣៥ | ២១ | ៤៩ | ៣៥ | ៤០ | ៤៤ | ១២៤ | ១០០ | ៥៥,៤% |
| កែប | អំពែង | ៤ | ៥២ | ១៣ | ៧០ | ១៣ | ៧២ | ៣០ | ១៩៤ | ១៣,៤% |
| | អូរក្រសា | ១៧ | ៤០ | ២៥ | ៥៩ | ២៥ | ៥៩ | ៦៧ | ១៥៨ | ២៩,៨% |
| **សរុបរួម** | | **៩៨** | **៣៥១** | **១៤៣** | **៥២៧** | **១៦៧** | **៥០៥** | **៤០៨** | **១៣៨៣** | **២២,៨%** |

ទូកនេសាទខ្នាតមធ្យម រួមមានទូកប្រវែង ១២-២៤ ម៉ែត្រ ទូកអូសទាំងអស់ និងទូកនេសាទ ដែលប្រើឧបករណ៍ អួនអូសគ្រែងឈាម ដោយមិនគិតពីប្រវែងទូក។

## ២.១ របាយការណ៍ផលនេសាទ

របាយការណ៍ផលនេសាទដោយធ្វើការប្រៀបធៀបរវាងខែនិងខេត្ត ដូចបង្ហាញ ក្នុងរូបភាពទី១ បានបង្ហាញយ៉ាងច្បាស់ថាផលនេសាទខ្ពស់ជាងគេមាន ២ខែ គឺនៅខែឧសភា និងខែកក្កដា ឆ្នាំ២០២២ ដែលខែទាំងពីរ ស្ថិតនៅក្នុងខេត្តកោះកុង។ លទ្ធផលនេះមិនមានទំនាក់ទំនងនឹងរដូវកាលនោះទេ ផលនេសាទខ្ពស់សម្រាប់ខែឧសភា គឺបណ្តាលមកពីការដាក់ការឡើងផលនេសាទចំនួន៤ ដោយប្រើឧបករណ៍មងហ៊ុំ ចូលគ្នា ដែលមានកត់ត្រាសម្រាប់តែខែឧសភា រីឯផលនេសាទខ្ពស់នៅខែកក្កដា គឺដោយ សារការឡើងផលនេសាទពីទូកអួនអូស មានមធ្យមខ្ពស់ជាងខែផ្សេងៗ។




**រូបភាពទី១.** ផលនេសាទសរុបកត់ត្រាតាមទម្ងន់ (គ.ក្រ) តាមខេត្តនិងខែ

មិនឃើញមានភាពផ្សេងគ្នាតាមរដូវកាលសម្រាប់ខេត្តផ្សេងទៀត ហើយភាពខុសគ្នារវាងខែក្នុងខេត្តដូចគ្នាភាគច្រើនបណ្តាលមកពីការយកគំរូចៃដន្យនៃឧបករណ៍ជាក់លាក់ឬការអង្កេតលើទូកនេសាទមានទំហំធំជាងនៅគ្រាខ្លះ។

## ២.២ របាយការណ៍ផលនេសាទតាមឧបករណ៍

ផលនេសាទជាមធ្យម ដែលបានរាយការណ៍ តាមការឡើងផលនេសាទ មានបង្ហាញជូននៅក្នុងតារាងទី២ សម្រាប់ឆ្នាំ២០២២ ដោយយកទិន្នន័យទាំង ៨ខែ ដាក់បញ្ចូលគ្នា។ ឧបករណ៍នេសាទណា ដែលត្រូវបានគេសង្កេតឃើញមាននៅក្នុងការឡើងផលនេសាទតែ១ ត្រូវបានលុបចេញ។ លទ្ធផលបង្ហាញពីភាពខុសគ្នានៃផលនេសាទដោយឧបករណ៍នេសាទដូចគ្នារវាងថ្នាក់ទូកនេសាទ។

ភាពជាក់លាក់តាមបែបស្ថិតិ ដូចបង្ហាញជូនអាចទទួលយកបានសម្រាប់ការរួមបញ្ចូលគ្នារវាងទូកនេសាទ-ឧបករណ៍ភាគច្រើន ដោយមានតែឧបករណ៍មួយចំនួនប៉ុណ្ណោះ ឧ.មងត្រី សន្ទូចមឹក និងមងហ៊ំ ដែលបង្ហាញបម្រែបម្រួលខ្ពស់ ភាគច្រើនដោយសារភាពខុសគ្នានៃចំនួនឧបករណ៍ ដែលបានបម្រើធ្វើនេសាទ ឬដោយសារតែកំណត់ត្រាមិនគ្រប់គ្រាន់ ដូចជា មងបង្កងប៉ាក សន្ទូចបបែល មងត្រីកន្ទាំង និងលបមឹក ជាដើម។

**តារាងទី២.** របាយការណ៍ផលនេសាទមធ្យមរាល់ការឡើងផលនេសាទដោយឧបករណ៍តែ១ ក្នុងឆ្នាំ២០២២

| ឧបករណ៍នេសាទ | កំណត់ត្រាការឡើងផលនេសាទ | ខ្នាតតូច | | ខ្នាតមធ្យម | |
|---|---|---|---|---|---|
| | | មធ្យម | ε% | មធ្យម | ε% |
| អួនអូស | ៧៦៤ | | | ៤៩០,៩ | ១១,៧% |
| មងក្លាម | ២៣៦ | ៤៤,៩ | ១៩,៧% | ៤៩,៨ | ១១,៦% |
| មងត្រី | ១៧៩ | ៤៩,៨ | ១១,៩% | ៥៣១,៥ | ១២,៨% |
| លបក្តាម | ១០២ | ១៤,៦ | ៩,៨% | ១២៣,៦ | ២៩,៨% |
| លបត្រីម្រេមព្រះ | ៩៩ | ១៤,៣ | ១២,៨% | ២៤,៧ | ៧,៣% |
| មងត្រីកាម៉ុង | ៩៣ | ៥០,៣ | ២៦,៣% | ៤៣៤,២ | ១៦,៣% |
| សន្ទូចសម្រាប់ចាប់មឹក | ៤១ | ២៦២,៩ | ១៣,២% | ២៥៩,០ | ១១,១% |
| ឈឺប ឌុន | ៤១ | ៤០,៧ | ១២,៣% | ៣៤,២ | ២០,៥% |
| មងបង្គារ | ៤០ | ៣៥២,៨ | ៥២,៣% | ៩១៧,០ | ៥៨,៣% |
| លបត្រី | ១១ | ៨០០,៥ | ៧៤,៩% | ១០៤២,៨ | ៨,៤% |
| មងត្រីផ្ទោង | ១១ | | | ១៦៦៦,៧ | ៦,៣% |
| សន្ទូចនោងចាប់បង្គារ | ១០ | ៣,២ | ៦២,១% | ២៤៩,០ | ៤១,៩% |
| ខ្វាវគ្រែងឈាម | ៧ | | | ៤,៩ | ១៩,៤% |
| មងត្រីកាការ | ៦ | ១១,៥ | ១៥,៦% | | |
| សន្ទូចនោងចាប់បង្គារ | ៥ | ៣៥,០ | ៧១,៤% | ២៥៦,៧ | ១៦,៩% |
| លបខ្យង | ៥ | | | ៧៧,២ | ២៨,៧% |
| មងហ៊ុំ | ៤ | | | ១៣៦៨៥,០ | ៤៥,៥% |
| មងត្រីក្បក | ៤ | ២២,៥ | ១៣,៩% | | |
| រនាស់អូសគ្រុំក្រឡាហូល | ៣ | ៥៨៥,០ | ៣,០% | | |
| សន្ទូចនោងចាប់ត្រី | ៣ | ១០,៥ | ១៤,៣% | | |
| មងបង្កងប៉ាក | ៣ | | | ៧,៩ | ៣៤,២% |
| សន្ទូចមឹក | ៣ | ១២,២ | ៥២,៨% | | |
| មងត្រីកន្តាំង | ៣ | ៧១,៧ | ៤១,៩% | | |
| លបបង្គារ | ៣ | ៩៧,០ | ៣៦,០% | | |
| សន្ទូចត្រី | ២ | ១៧,៥ | ១៤,៣% | | |
| **ឈឺបរុញដោយដៃ** | ២ | ១១,៥ | ១៣,០% | | |
| **មងបង្គាបីជាន់** | ២ | ៦,៧ | ២០,៣% | | |

កម្រិតលំអៀងស្តង់ដារសមស្របបង្ហាញដោយតម្លៃ ε% ប្រសិនបើ ε% ខ្ពស់ជាង ៣០% បញ្ជាក់ថាតម្លៃមិនមានភាពត្រឹមត្រូវតាមន័យស្ថិតិនិងមិនអាចប្រើបាន។ ផលនេសាទជាមធ្យមដោយផ្អែកលើការសង្កេតតែមួយ មិនអាចតំណាងអោយឧបករណ៍នោះ ហើយមិនត្រូវបានរាប់បញ្ចូលក្នុងតារាងគណនានោះទេ។

ផលនេសាទប្រចាំថ្ងៃត្រូវបានគណនា ដោយយកឧបករណ៍ចាប់បានកំពូលគេទាំង ១៥ នៅក្នុងតារាងទី៣ ដោយផ្អែកលើទម្ងន់ ដែលបានរាយការណ៍ និងរយៈពេលធ្វើដំណើរនេសាទ។ ទោះបីជាចំនួនថ្ងៃធ្វើនេសាទ ដែលរួមចំណែកដល់ផលនេសាទ មិនត្រូវបានកត់ត្រាជាប្រចាំ គ្រប់ការឡើងផលនេសាទក៏ដោយ ការគណនាតាមវិធីនេះផ្តល់នូវការប៉ាន់ប្រមាណកាន់តែប្រសើរឡើងសម្រាប់ទិន្នផលនេសាទសមស្របនៃឧបករណ៍ផ្សេងៗគ្នា និងធ្វើការប៉ាន់ប្រមាណពីផលនេសាទតាមការឡើងផលនេសាទ។

**តារាងទី៣** មធ្យមផលនេសាទប្រចាំថ្ងៃ (គីឡូក្រាម/ថ្ងៃ) ដែលមានសារៈសំខាន់តាមន័យស្ថិតិសម្រាប់ភាពខុសគ្នារវាងការនេសាទខ្នាតតូច និងមធ្យម

| ឧបករណ៍នេសាទ | ខ្នាតតូច | | | ខ្នាតមធ្យម | | | P |
|---|---|---|---|---|---|---|---|
| | មធ្យម | ε% | SD | មធ្យម | ε% | SD | |
| អួនអូស | | | | ២១១,៣ | ៦,២% | ១៥៩២,0 | - |
| មងក្តាម | ១៦,២ | ១២,១% | ៧៣,៩ | ២១,0 | ៧,៤% | ៧៤,៧ | 0,0៤៩២ |
| មងត្រី | ៣៥,៩ | ៦,៥% | ៦៤,0 | ៨៩,៣ | ៩,0% | ៥៣៤,៤ | <0,000១ |
| លបក្តាម | ១៣,៨ | ១0,១% | ៧,៩ | ២៦,១ | ៦,៩% | ៣១២,១ | <0,000១ |
| លបត្រីម្រើមព្រះ | ១៤,៣ | ១២,៨% | ១១,១ | ២១,៣ | ៧,៩% | ១៤,១ | 0,00៥៦ |
| មងត្រីកាម៉ុង | ៤៨,៤ | ២៧,៦% | ៥៩,២ | ១0១,២ | ១២,១% | ៦0៥,0 | 0,00៣៥ |
| សន្ទូចមឹក | ៤0,៣ | ១0,៤% | ៩២,១ | ៥0,៤ | ៦,៨% | ១៦៨,២ | 0,0៨១៣ |
| ឈឺប ឌុន | ៤0,៧ | ១២,៣% | ២៧,១ | ៣៤,២ | ២0,៥% | ២៤,៣ | 0,៤៥៩៥ |
| មងបង្គារ | ១00,២ | ៥៧,៤% | ៤៥១,៩ | ៩0,១ | ៣៨,៥% | ៣១១៦,៦ | 0,៨៨៣២ |
| លបត្រី | ១៥៨,៨ | ២៦,៥% | ៨៤៧,៨ | ៨៦,៩ | ១១,១% | ២៦៣,៦ | 0,៣២៦៤ |
| មងត្រីផ្ទោង | | | | ១៥១,៦ | ១៧,២% | ៣៣២,៦ | - |
| សន្ទូចចាប់បង្គារ | ៣,២ | ៦២,១% | ៣,៤ | ២៧,១ | ១៧,៥% | ២៧៦,២ | 0,00១៩ |
| ខ្វាវគ្រែងឈាម | | | - | ៤,៩ | ១៩,៤% | ២,៥ | - |
| មងត្រីការ៉ាវ | ១១,៥ | ១៥,៦% | ៤,៤ | | | - | - |
| សន្ទូចចាប់មឹក | ៦,0 | ៤៤,0% | ៣៥,៤ | ២៨,0 | ១៤,៩% | ៧៥,១ | 0,0២១២ |

ផលនេសាទប្រចាំថ្ងៃត្រូវបានគណនាដោយផ្អែកលើទម្ងន់ផលនេសាទសរុប ដែលបានរាយការណ៍ និងចំនួនថ្ងៃធ្វើនេសាទ។ តម្លៃ p< 0,0៥ បង្ហាញពីភាពខុសគ្នាខ្លាំងតាមន័យស្ថិតិរវាងផលនេសាទមធ្យម រវាងការនេសាទខ្នាតតូច និងខ្នាតមធ្យម។ ចំពោះតម្លៃ ε%> ៣0% មានន័យថាតម្លៃមធ្យមគឺមិនត្រឹមត្រូវតាមបែបស្ថិតិ ហើយមិនគួរប្រើប្រាស់ទេ។

ទូកអួនអូសមានផលនេសាទប្រចាំថ្ងៃខ្ពស់បំផុតគឺ ២១១ គីឡូក្រាម/ថ្ងៃ បន្ទាប់មក ឧបករណ៍នេសាទ ដែលមានបម្រែបម្រួលផលនេសាទខ្ពស់ គឺឧបករណ៍លបនិងមងត្រីផ្ទោង។ សម្រាប់ឧបករណ៍ផ្សេងទៀត មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងផលនេសាទប្រចាំថ្ងៃ តាមទូកនេសាទខ្នាតតូច និងខ្នាតមធ្យម ដោយផលនេសាទពីឧបករណ៍

មងនិងលប មានការប្រែប្រួលទៅតាមទំហំទូកនេសាទ (និងកម្លាំងម៉ាស៊ីន) ទាក់ទងនឹងចំនួនឧបករណ៍ ដែលអាចប្រើនេសាទនិងចម្ងាយ ដែលទូកនេសាទអាចធ្វើដំណើរទៅនេសាទលើដែនសមុទ្រ។

ផលនេសាទប្រចាំថ្ងៃតាមឧបករណ៍ តាមខេត្តនីមួយៗ មានបង្ហាញជូនក្នុងឧបសម្ព័ន្ធ៣។

**តារាងទី៤** សមាមាត្រនៃការឡើងផលនេសាទ ដែលបានកត់ត្រាតាមឧបករណ៍ទាំងអស់ តាមខេត្ត ជាមួយនឹងការរួមចំណែកទៅនឹងផលនេសាទ ដែលបានកត់ត្រា (គីឡូក្រាម)

| ឧបករណ៍នេសាទ | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុបរួម | %សរុប |
|---|---|---|---|---|---|---|
| អួនអូស | ៣៣,៩% | ៦១,១% | ២,៦% | ២,៤% | ៣៧៥ ០៧៤,៣ | ៥៩,៤៩% |
| មងហ៊ុំ | ១០០,០% | - | - | - | ៥៤ ៧៤០,០ | ៨,៦៨% |
| មងត្រី | ៩,៥% | ៥១,៤% | ៣៧,៦% | ១,៦% | ៣៨ ៧៨០,៥ | ៦,១៥% |
| មងបង្គារ | ៩៧,៥% | ២,៤% | - | - | ៣៣ ២៩៤,១ | ៥,២៨% |
| មងត្រីកាម៉ុង | ១៨,៥% | ៤៦,០% | ៣៥,៤% | ០,១% | ៣២ ៧០៣,០ | ៥,១៩% |
| ផ្សេងទៀត | ៩៥,១% | - | ៣,៥% | ១,៤% | ២៥ ១៣៣,៧ | ៣,៩៩% |
| មងត្រីផ្ទោង | ០,៣% | - | ៩៩,៧% | - | ១៦ ៧២៤,០ | ២,៦៥% |
| មងក្ដាម | ៤,០% | ៧៤,៨% | ០,៣% | ២០,៩% | ១១ ៤១៥,៣ | ១,៨១% |
| លបត្រី | ៩៨,២% | - | ១,៨% | - | ១០ ៩៨៦,០ | ១,៧៤% |
| សន្ទូចមឹក | ៩១,៩% | ៤,៩% | - | ៣,២% | ១០ ៦៤៥,០ | ១,៦៩% |
| លបក្ដាម | ៧៧,២% | ០,៤% | ១៤,២% | ៨,២% | ៩ ៣៣៨,១ | ១,៤៨% |
| លបត្រីម្រើមព្រះ | ១៥,៤% | - | ០,៥% | ៨៤,២% | ២០៦០,០ | ០,៣៣% |
| រនាស់អូសគ្រុំក្រឡាហូល | ១០០,០% | - | - | - | ១៧៥៥,០ | ០,២៨% |
| សន្ទូចអូសមឹក | ៩៧,៦% | - | - | ២,៤% | ១៧៥២,៥ | ០,២៨% |
| ឈឺម ឌុន | ១០០,០% | - | - | - | ១៥៩០,៧ | ០,២៥% |
| **មងត្រីបេកា** | ៤០,០% | ៦០,០% | - | - | ១៥០០,០ | ០,២៤% |
| សន្ទូចរនងមឹក | ៩៨,៨% | - | - | ១,២% | ៨៤០,០ | ០,១៣% |
| អួនកាកឹម | ១០០,០% | - | - | - | ៧០០,០ | ០,១១% |
| លបខ្យង | ៦៣,៧% | ៣៦,៣% | - | - | ៣៨៦,០ | ០,០៦% |
| លបមឹក | ៨៩,៣% | - | ១០,៧% | - | ២៩១,០ | ០,០៥% |
| មងត្រីកន្ទាំង | - | - | ១០០,០% | - | ២១៥,០ | ០,០៣% |
| ការរកអយស្ទ័រ | - | - | ១០០,០% | - | ៩២,០ | ០,០១% |
| មងត្រីក្បក | ៨២,២% | - | ១៧,៨% | - | ៩០,០ | ០,០១% |
| មងត្រីការ៉ាវ | ២៩,១% | - | ៧០,៩% | - | ៦៨,៨ | ០,០១% |
| សន្ទូចបបេល | - | - | - | ១០០,០% | ៣៦,៥ | ០,០១% |

| ឧបករណ៍នេសាទ | កោះកុង | ព្រះសីហនុ | កំពត | កែប | សរុបរួម | %សរុប |
|---|---|---|---|---|---|---|
| សន្ទូចត្រី | ៥៧,១% | - | - | ៤២,៩% | ៣៥,០ | ០,០១% |
| ខ្វាវគ្រែងឈាម | ១០០,០% | - | - | - | ៣៤,៥ | ០,០១% |
| សន្ទូចរនង | ៧១,៤% | - | ២៨,៦% | - | ៣១,៥ | <០,០១% |
| ចាប់ដោយដៃ | - | - | - | ១០០,០% | ៣០,០ | <០,០១% |
| មងបង្កងប៉ាក | ១០០,០% | - | - | - | ២៣,៨ | <០,០១% |
| ឈឺបរុញដោយដៃ | - | - | ១០០,០% | - | ២៣,០ | <០,០១% |
| មងបង្គាបីជាន់ | - | - | ១០០,០% | - | ១៣,៣ | <០,០១% |
| សន្ទូចរនងស្រទាប់បាត | - | - | - | ១០០,០% | ១២,០ | <០,០១% |
| លប | - | - | ១០០,០% | - | ១២,០ | <០,០១% |
| ស្នារ | ១០០,០% | - | - | - | ៥,៥ | <០,០១% |
| សរុបរួម | ៤៥,១% | ៤៣,៦% | ៨,៨% | ២,៤% | ៦៣០.៤៣២,១ | |

ទិន្នន័យក្នុងតារាងទី៤មិនរាប់បញ្ចូលការឡើងផលនេសាទ ដោយប្រើពហុឧបករណ៍ ដែលបានរួមចំណែកដល់ផលនេសាទ ៦.០០៤ គីឡូក្រាម ឬតិចជាង ១% នៃផលនេសាទសរុប ដែលបានរាយការណ៍ ក្នុងចំណោមការឡើងផលនេសាទទាំង ៤៤ លើក ដែលភាគច្រើនជាការឡើងផលនេសាទនៅខេត្តព្រះសីហនុ។ ភាគច្រើននៃការឡើងផលនេសាទដោយប្រើពហុឧបករណ៍ ជាការនេសាទប្រើប្រាស់ឧបករណ៍នេសាទផ្សំគ្នារវាងមងសម្រាប់ចាប់ត្រីក្តាម និងបង្គា។ ការឡើងផលនេសាទដោយពហុឧបករណ៍បានរួមចំណែក ៨៤% នៃការឡើងផលនេសាទ និង ៧៦% នៃផលនេសាទ ដែលបានរាយការណ៍សម្រាប់ការឡើងផលនេសាទដោយពហុឧបករណ៍នេះ។

ដូចបង្ហាញក្នុងតារាងទី៤ និងរូបភាពទី២ ប្រមាណជា ៦០% នៃផលនេសាទ ដែលបានរាយការណ៍ បានមកពីការនេសាទដោយទូកអួនអូស ភាគច្រើនជាទូកអួនអូស មកពីខេត្តព្រះសីហនុ និងខេត្តកោះកុង មងហ៊ុំរួមចំណែក ៨,៧% និង មងត្រី មងបង្គា និងមងត្រីកាម៉ុង ដែលឧបការណ៍នីមួយៗ រួមមាន រួមចំណែក ៥-៦%។ ប្រហែល ៤% នៃផលនេសាទត្រូវបានគេសន្មតថាជាឧបករណ៍មិនកំណត់ជាក់លាក់ ដែលភាគច្រើននៅខេត្តកោះកុង។

តារាងទី៤ គូសបញ្ជាក់បន្ថែមអំពីការឡើងផលនេសាទដោយឧបករណ៍មួយចំនួន ដែលបានសង្កេតឃើញមានតែនៅក្នុងខេត្តមួយប៉ុណ្ណោះ។ របាយការណ៍នេះមិនសមស្របនឹងព័ត៌មាន ដែលមាននៅក្នុងមូលដ្ឋានទិន្នន័យជំរឿនទូកនេសាទ (ឆ្នាំ២០១៨) និងបង្ហាញពីភាពស្មុគស្មាញដល់ការប៉ាន់ប្រមាណផលនេសាទសរុបតាមខេត្ត ដោយការប៉ាន់ប្រមាណអំពីផលនេសាទមធ្យមនិងកម្លាំងធ្វើនេសាទតាមខេត្ត ផ្អែកលើមូលដ្ឋាន ឧបករណ៍-ទូកនេសាទ។ ដោយការកានេសាទដោយទូកអួនអូស ភាគច្រើនត្រូវបានគេកត់ត្រានៅខេត្តព្រះសីហនុ ការប៉ាន់ប្រមាណនេះមិនអាចតំណាងអោយផលនេសាទក្នុងខេត្តផ្សេងទៀត ដែលអាចធ្វើឱ្យប៉ះពាល់ដល់តម្លៃនៃការប៉ាន់ស្មាន។




**រូបភាពទី២.** ការរួមចំណែកនៃប្រភេទឧបករណ៍ចម្បងៗ ដល់ផលនេសាទសរុប ដែលបានរាយការណ៍ តាមការឡើងផលនេសាទ ដែលបានកត់ត្រា (ផលនេសាទសរុប ដែលបានរាយការណ៍: ៦៣៦.៤៣៦ គីឡូក្រាម)




**រូបភាពទី៣.** ទីតាំងធ្វើនេសាទរាយការណ៍តាមឧបករណ៍ទាំងអស់រួមបញ្ចូលគ្នា និងរាយការណ៍ដោយឡែកសម្រាប់ទូកអួនអូស

ទីតាំងទូទៅ ដែលទូកនេសាទធ្វើប្រតិបត្តិការ ជាពិសេសកំណត់ថាតើផលនេសាទ ដែលបានរាយការណ៍ត្រូវបានធ្វើឡើងនៅក្នុងសមុទ្រក្នុង ឬសមុទ្រក្រៅ មានបង្ហាញនៅក្នុងរូបភាពទី៣។ របាយកាណ៍នេះបង្ហាញអំពីសមាមាត្រ នៃផលនេសាទដ៏សន្ធឹកសន្ធាប់ ត្រូវបានគេរាយការណ៍បានមកពីតំបន់សមុទ្រក្នុង (ក្នុងខ្សែបន្ទាត់ជម្រៅ ២០ ម៉ែត្រ) ក្នុងនោះក៏មានរួមទាំងការនេសាទដោយទូកអួនអូសផងដែរ។ តាមការរំពឹងទុក ផលនេសាទភាគច្រើនត្រូវបានគេរាយការណ៍ថានេសាទនៅសមុទ្រក្រៅ ហើយអ្នកនេសាទជាច្រើនមិនដឹងទីតាំងធ្វើនេសាទពិតប្រាកដ ឬស្គាល់ពីបន្ទាត់ព្រំដែន កំណត់សមុទ្រក្នុង និងសមុទ្រក្រៅ។

## ២.៣ កម្លាំងធ្វើនេសាទ

ការតាមដានវាយតម្លៃផលនេសាទសមុទ្រក្នុងប្រទេសកម្ពុជា (FCMAS) ឆ្នាំ២០២២ ប្រមូលទិន្នន័យអំពីចំនួនថ្ងៃធ្វើនេសាទ ដើម្បីធ្វើការគណនាអំពីកម្លាំងធ្វើនេសាទ តាមថ្នាក់ទូកនេសាទ-ឧបករណ៍។ ទិន្នន័យនេះត្រូវបានប្រើ ដើម្បីប៉ាន់ប្រមាណថ្ងៃធ្វើនេសាទប្រចាំខែតាមថ្នាក់ទូកនេសាទ តាមខេត្ត ក្នុងតារាងទី៥។ ការគណនានេះបង្ហាញថាមានភាពខុសប្លែកគ្នាតិចតួចរវាងថ្នាក់ទូកនេសាទ-ឧបករណ៍ និងខេត្ត ដោយមានកម្លាំងធ្វើនេសាទជាមធ្យមចន្លោះពី ១៦-២២ ថ្ងៃ/ខែ (ការប៉ាន់ប្រមាណទាំងអស់ត្រឹមត្រូវតាមន័យស្ថិតិ)។ ការធ្វើនេសាទផ្សេងពីឧបករណ៍ទូកអួនអូសនៅខេត្តកែប មានកម្លាំងធ្វើនេសាទទាប និងទូកនេសាទខ្នាតមធ្យម > ១៨ ម៉ែត្រ ក្នុងខេត្តកំពត ដែលបង្ហាញពីកម្លាំងធ្វើនេសាទខ្ពស់ជាងនៅខេត្តផ្សេងទៀត។

តារាងទី៥. ថ្ងៃធ្វើនេសាទប៉ាន់ប្រមាណជាមធ្យមប្រចាំខែ តាមថ្នាក់ឧបករណ៍ និងតាមខេត្ត

| ថ្នាក់ទូកនេសាទ-ឧបករណ៍ | កោះកុង | | ព្រះសីហនុ | | កំពត | | កែប | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|
| | ថ្ងៃ | ε% | ថ្ងៃ | ε% | ថ្ងៃ | ε% | ថ្ងៃ | ε% | ថ្ងៃ | ε% |
| ខ្នាតតូច | ១៧,៩ | ៣,២% | ១៩,២ | ៦,៤% | ២០,៧ | ២,៥% | ១៥,0 | ៥,១% | ១៨,២ | ១,៩% |
| ខ្នាតមធ្យម ១២-១៨ម | ១៦,៤ | ៣,៣% | ២១,៧ | ២,១% | ១៩,៥ | ៣,២% | ១២,៣ | ៥,0% | ១៦,៦ | ២,0% |
| ខ្នាតធម្យម >១៨ម | ២០,៥ | ៧,១% | ២០,៩ | ៣,៧% | ២៥,៩ | ៣,៧% | ១៣,៧ | ១៥,២% | ២០,៣ | ៣,៧% |
| អួនអូស <១២ម | ១៨,៤ | ៥,៤% | ២១,៩ | ៣,៣% | ១៧,៩ | ២,0% | ២១,៥ | ១,៨% | ១៩,៦ | ១,៣% |
| អួនអួន ១២-១៨ម | ១៧,៧ | ៦,0% | ២២,១ | ១,២% | ១៩,៦ | ៤,១% | ២២,៣ | ៥,0% | ២១,២ | ១,៣% |
| អួនអូស >១៨ម | ១៦,0 | ២៤,៧% | ២១,៥ | ៤,៤% | | | | | ២០,៦ | ៥,១% |

**ចំណាំ៖** ទូកនេសាទខ្នាតមធ្យម តំណាងឱ្យទូកនេសាទខ្នាតមធ្យមទាំងអស់ លើកលែងតែទូកនេសាទ កំពុងប្រើឧបករណ៍អួនអូស

សម្រាប់កម្លាំងធ្វើនេសាទតាមប្រភេទឧបករណ៍ (តារាងទី៦) កម្លាំងធ្វើនេសាទគឺស្រដៀងគ្នាខ្លាំងណាស់ តាមឧបករណ៍ និងតាមថ្នាក់ទូកនេសាទផ្សេងៗគ្នា ដោយមានភាពផ្សេងគ្នាតិចតួចប៉ុណ្ណោះ។ នេះបង្ហាញថា កម្លាំងធ្វើនេសាទភាគច្រើនមានលក្ខណៈឯករាជ្យពីប្រភេទ ឧបករណ៍-ទូកនេសាទ ដោយអ្នកនេសាទភាគច្រើន កំណត់គោលដៅនេសាទពេញម៉ោង។

**តារាងទី៦.** ថ្ងៃធ្វើនេសាទប៉ាន់ប្រមាណជាមធ្យមប្រចាំខែ តាមឧបករណ៍

| ឧបករណ៍នេសាទ | ខ្នាតតូច | | ខ្នាតមធ្យម | |
|---|---|---|---|---|
| | ថ្ងៃ | ε% | ថ្ងៃ | ε% |
| **អួនអូស** | | | ២០,៣ | ០,៩% |
| មងក្តាម | ១៦,៦ | ៥,២% | ១៣,០ | ៥,០% |
| មងត្រី | ១៩,៨ | ៣,០% | ២១,០ | ៣,៦% |
| លបក្តាម | ១៧,៦ | ៦,៨% | ១៧,៧ | ៤,០% |
| លបត្រីម្រើមព្រះ | ១៨,១ | ៦,៩% | ១៥,៨ | ៥,៧% |
| មងត្រីកាម៉ុង | ២០,៧ | ៨,៥% | ២២,៦ | ៣,១% |
| សន្ទូចមឹក | ១៧,៣ | ១៨,១% | ១៤,០ | ៧,៨% |
| ឈឺមឌុន | ១៩,១ | ៥,៣% | ១៧,៣ | ៨,៧% |
| មងបង្គា | ១៧,៨ | ៧,០% | ១៩,០ | ៥,៦% |
| លបត្រី | ១៦,០ | ២៥,០% | ១៦,០ | ១០,៣% |
| មងត្រីផ្ទោង | | | ២៥,៣ | ៥,០% |
| សន្ទូចអូសមឹក | ១១,៧ | ៤៦,០% | ១៦,៩ | ១២,១% |
| ឈ្នាងអូសគ្រែងឈាម | | | ១៦,១ | ១៩,៦% |
| មងត្រីការ៉ាវ | ២២,០ | ៥,៩% | | |
| សន្ទូចរនងមឹក | ២១,៥ | ៣០,២% | ១០,០ | ២៨,៩% |
| លបខ្យង | | | ១៥,៤ | ១៩,៤% |
| មងហ៊ុំ | | | ២៥,០ | ១០,៦% |
| រនាស់អូសគ្រុំក្រឡាហូល | ១៦,០ | ១៣,០% | | |
| សន្ទូចរនង | ១៦,០ | ៦,៣% | | |
| មងបង្កងប៉ាក | | | ១៧,៣ | ៣៩,០% |
| សន្ទូចបបែល | ៦,៧ | ២១,៨% | | |
| មងត្រីកន្តាំង | ២៤,០ | ១២,៥% | | |
| លបមឹក | ១៩,០ | ៥,៣% | | |
| សន្ទូចត្រី | ១៣,០ | ៦៩,២% | | |
| ឈឺបរុញដោយដៃ | ២១,៥ | ៣០,២% | | |
| មងត្រីក្បក | ១៨,៥ | ៣៥,១% | | |
| មងបង្គាបីជាន់ | ២៦,៥ | ៥,៧% | | |

## ២.៤ ផលនេសាទនិងតម្លៃតាមប្រភេទ

ត្រីចូលរួមចំណែកភាគច្រើននៃផលនេសាទតាមទម្ងន់ ដូចមានបង្ហាញក្នុងរូបភាពទី៤ បន្ទាប់មកគឺក្រុមបង្គារ ពពួកមឹក និងក្តាម។




រូបភាពទី៤. ការចូលរួមចំណែកនៃក្រុមវារីសត្វសំខាន់ៗ ទៅនឹងរបាយការណ៍ផលនេសាទ (ផលនេសាទសរុប: ៦៣៦.៤៣៦ គីឡូក្រាម)

ត្រីកាកីម ដែលជាប្រភេទត្រីចម្រុះមិនបានបញ្ជាក់និងជាត្រីជី (ត្រីមានតម្លៃទាប ដែលប្រើជាចម្បងសម្រាប់ផលិតចំណីត្រី) រួមចំណែកប្រមាណ ៥០% នៃផលនេសាទ ដែលបានរាយការណ៍ (តារាងទី៧)។ ប្រភេទនិងក្រុមប្រភេទផ្សេងទៀតរួមចំណែកតិចជាងខ្លាំងណាស់ទៅនឹងផលនេសាទ។ ប្រភេទ នេសាទបានច្រើនជាងគេ ទាំង ២០ប្រភេទ ផ្អែកលើទម្ងន់ រួមចំណែកច្រើនជាង ៨៦% នៃផលនេសាទ ដែលបានរាយការណ៍។

ដោយសារតែសមាមាត្រដ៏ធំធេងនៃត្រីផ្សេងទៀតនិងត្រីជីទៅនឹងផលនេសាទ ដែលបានរាយការណ៍ មានផលនេសាទប្រមាណ ៣៧% មិនត្រូវបានគេរាយការណ៍តាមប្រភេទ ដោយមិនរាប់បញ្ចូលត្រីផ្សេងៗ ដែលចាត់ទុកជាត្រីជី មានផលនេសាទ ច្រើនជាង ២៩% ត្រូវបានគេរាយការណ៍តាមក្រុមប្រភេទ។

**តារាងទី៧.** របាយការណ៍ប្រភេទនិងក្រុមប្រភេទ នេសាទបានខ្ពស់បំផុតទាំង ២០ប្រភេទ **តាមទម្ងន់** (គីឡូក្រាម)

| | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះជាភាសាអង់គ្លេស | ផលនេសាទ (គ.ក្រ) | ផលនេសាទ % | |
|---|---|---|---|---|---|
| | | | | %សរុប | %បង្គរ |
| 1 | *Encrasicholina heteroloba* | Shorthead anchovy | ១៩៤ ៨៨០,0 | ៣0,៦% | ៣0,៦% |
| 2 | | Other fish nei | ៧៥ ៤៤៧,៥ | ១១,៩% | ៤២,៥% |
| 3 | | trash fish | ៥0 ៦៤៣,៨ | ៨,0% | ៥0,៤% |
| 4 | *Penaeus sp.* | Prawns nei | ២៦ 0៤១,២ | ៤,១% | ៥៤,៥% |
| 5 | *Portunus pelagicus* | Swimming crab | ២៣ ៧២២,៧ | ៣,៧% | ៥៨,៣% |
| 6 | | Needlefish nei | ២២ ៧៤0,0 | ៣,៦% | ៦១,៨% |
| 7 | *Metapenaeus spp.* | | ២១ ២៦៩,0 | ៣,៣% | ៦៥,២% |
| 8 | | Mollusks nei | ១៨ ៧១0,៣ | ២,៩% | ៦៨,១% |
| 9 | | Squids nei | ១៦ ៥៨៨,៨ | ២,៦% | ៧0,៧% |
| 10 | *Decapterus macrosoma* | Shortfin scad | ១៥ ៤១៨,0 | ២,៤% | ៧៣,១% |
| 11 | *Atule mate* | Yellowtail scad | ១៥ 00១,0 | ២,៤% | ៧៥,៥% |
| 12 | | Octopus | ១0 ៦៤៦,១ | ១,៧% | ៧៧,២% |
| 13 | *Rastrelliger brachysoma* | Short mackerel | ១0 0៧៦,0 | ១,៦% | ៧៨,៧% |
| 14 | *Stolephorus indicus* | Indian anchovy | ១0 0៤១,0 | ១,៦% | ៨0,៣% |
| 15 | | Pony fishes | ៧ ៦0៧,៥ | ១,២% | ៨១,៥% |
| 16 | *Scomberoides commersonianus* | Talang queenfish | ៧ ២0១,0 | ១,១% | ៨២,៧% |
| 17 | | Other catch nei | ៧ ១៨៦,៦ | ១,១% | ៨៣,៨% |
| 18 | | Shellfish nei | ៦ ៧៩១,0 | ១,១% | ៨៤,៨% |
| 19 | *Chirocentrus dorab* | Dorab wolf-herring | ៥ ៥២0,0 | 0,៩% | ៨៥,៧% |
| 20 | *Anodontostoma chacunda* | Chacunda gizzard shad | ៥ ៤៤0,0 | 0,៩% | ៨៦,៦% |
| | ប្រភេទដ៏ទៃទៀត | | ៨៥ ៤៦៤,៩ | ១៣,៤% | ១00,0% |
| | **ផលនេសាទរាយការណ៍សរុប** | | **៦៣៦.៤៣៦,៤** | | |

របាយការណ៍ប្រភេទសរុបតាមទម្ងន់ តាមខេត្ត មាននៅក្នុងឧបសម្ព័ន្ធ១។

ការរួមចំណែកនៃប្រភេទមិនមែនជាត្រី ដល់តម្លៃផលនេសាទសរុប (តារាងទី៨) ខ្ពស់ជាងការរួមចំណែករបស់វាទៅនឹងបរិមាណផលនេសាទ ដោយសារតែតម្លៃនៃពពួកមិនមែនត្រី ខ្ពស់ជាងខ្លាំង ហើយ ៥១% នៃផលនេសាទ ជាប្រភេទត្រី ជាការរួមគ្នានៃត្រីមានតម្លៃទាប ត្រីកាកីមនិងត្រីជី ដែលមានតម្លៃជាមធ្យម ៥00-១000 រៀល/គីឡូក្រាម ជាតម្លៃលក់នៅដើមគ្រា។ ត្រីតំណាងឱ្យតិចជាង ៣៨% នៃតម្លៃផលនេសាទសរុប ក្រៅពីនេះ ជាប្រភេទមិនមែនជា

ត្រី (រូបភាពទី៥)។ តម្លៃតាមប្រភេទ ឬក្រុមប្រភេទមិនត្រូវបានគេរាយការណ៍ពេញលេញ ឬ ក្រុមប្រភេទសម្រាប់ធ្វើពាណិជ្ជកម្ម (លក់ដូរ) មួយចំនួនត្រូវបានគេដាក់បញ្ចូលជាប្រភេទដាច់ដោយឡែក។




**រូបភាពទី៥.** របាយការណ៍សមាមាត្រនៃតម្លៃសរុប តាមក្រុមប្រភេទវារីសត្វសម្បូងៗ (តម្លៃសរុបៈ ៣.៣៩៧.៩៤៨.៥០០រៀល)

**តារាងទី៨.** របាយការណ៍ប្រភេទតាមតម្លៃ (១០០០រៀល) ខ្ពស់បំផុតទាំង២០ និងតម្លៃមធ្យម/មួយគីឡូក្រាម

| | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះជាភាសាអង់គ្លេស | តម្លៃ (១០០០រៀល) | %តម្លៃ | %កំណើន | ថ្លៃ (រៀល) |
|---|---|---|---|---|---|---|
| 1 | *Portunus pelagicus* | Swimming crab | ៦៦៦ ៦៦៦,៨ | ១៩,៦% | ១៩,៦% | ២៥ ៥០០,០ |
| 2 | | Squids nei | ៣៥៣ ២១៤,៧ | ១០,៤% | ៣០,០% | ១៩ ០០០,០ |
| 3 | *Penaeus sp.* | Prawns nei | ៣១៩ ៨៣៩,៦ | ៩,៤% | ៣៩,៤% | ១៨ ៥០០,០ |
| 4 | *Metapenaeus spp.* | | ២៨៥ ០៥៧,០ | ៨,៤% | ៤៧,៨% | ១៨ ៥០០,០ |
| 5 | *Encrasicholina heteroloba* | Shorthead anchovy | ២០៨ ៧៧៥,៦ | ៦,១% | ៥៤,០% | ១ ០០០,០ |
| 6 | | Other fish nei | ២០៤ ៦២៦,២ | ៦,០% | ៦០,០% | ៤ ០០០,០ |
| 7 | *Atule mate* | Yellowtail scad | ១២០ ០០៧,០ | ៣,៥% | ៦៣,៥% | ៧ ៥០០,០ |
| 8 | | Octopus | ១១៩ ១៧០,០ | ៣,៥% | ៦៧,០% | ១២ ៥០០,០ |
| 9 | | Needlefish nei | ១០៧ ៦០០,០ | ៣,២% | ៧០,២% | ៧ ០០០,០ |
| 10 | *Decapterus macrosoma* | Shortfin scad | ៩៩ ៧៩៩,៥ | ២,៩% | ៧៣,១% | ៦ ៥០០,០ |
| 11 | *Suborder Sepiina* | Cuttlefish | ៦៤ ២២៦,៥ | ១,៩% | ៧៥,០% | ១៤ ០០០,០ |
| 12 | | Cephalopods (squids/cuttlefish) | ៦២ ៦៧៣,១ | ១,៨% | ៧៦,៩% | ១៤ ០០០,០ |
| 13 | *Rastrelliger brachysoma* | Short mackerel | ៦២ ០៦៩,៥ | ១,៨% | ៧៨,៧% | ៦ ០០០,០ |

| | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះជាភាសាអង់គ្លេស | តម្លៃ (១០០០រៀល) | %តម្លៃ | %កំណើន | ថ្លៃ (រៀល) |
|---|---|---|---|---|---|---|
| 14 | *Scomberoides commersonianus* | Talang queenfish | ៦០ ២២៩,៥ | ១,៨% | ៨០,៥% | ៩ ០០០,០ |
| 15 | *Penaeus monodon* | Giant tiger prawn | ៥៨ ០៣៥,៦ | ១,៧% | ៨២,២% | ២៤ ៥០០,០ |
| 16 | *Euthynnus affinis* | Mackerel tuna | ៤៦ ២៥០,០ | ១,៤% | ៨៣,៥% | ៩ ០០០,០ |
| 17 | *Scomberomorus commerson* | Narrow-barred Spanish mackerel | ៤៣ ៧០០,០ | ១,៣% | ៨៤,៨% | ១០ ០០០,០ |
| 18 | | Other catch nei | ៤១ ៦៩២,០ | ១,២% | ៨៦,០% | |
| 19 | | trash fish | ៣៤ ៦៧២,៥ | ១,០% | ៨៧,១% | ៥០០,០ |
| 20 | | Mantis shrimp | ៣១ ០៦៤,៨ | ០,៩% | ៨៨,០% | ៥៧ ០០០,០ |
| | ប្រភេទដ៏ទៃទៀត | | ៤០៨ ៥៧៨,៥ | ១២,០% | ១០០,០% | |
| | | | | | | |
| | **តម្លៃរាយការណ៍សរុបតាមប្រភេទ** | | ៣ ៣៩៧ ៩៤៨,៥ | | | |

ប្រភេទ ដែលមានតម្លៃខ្ពស់រួមមាន បង្គា បង្កង មឹក និងក្តាម (ជាពិសេសក្តាមថ្ម)។ ទោះជាយ៉ាងណាក៏ដោយ ប្រភេទ ដែលមានតម្លៃខ្ពស់ភាគច្រើន នេសាទបានតិចបំផុត ប្រភេទ ដែលមានតម្លៃខ្ពស់បំផុត ទាំង ៣ ប្រភេទ រួមមាន ៖ អន្ទង់សមុទ្រ (១៥០.០០០រៀល) បង្កង (៦០.០០០រៀល) និងបង្កងប៉ាក (៥៧.០០០រៀល) ដែលនេសាទបានតិចតួចណាស់ ដោយបង្កងប៉ាករួមចំណែកទៅនឹងផលនេសាទ ៨០៧ គ.ក្រ (០,១៣%) នៃផលនេសាទរាយការណ៍សរុប។ តម្លៃប្រភេទ ដែលបានរាយការណ៍សរុបតាមខេត្តនីមួយៗ មាននៅក្នុងឧបសម្ព័ន្ធ២។

## ២.៥ ការប៉ាន់ប្រមាណផលនេសាទសរុប

ទោះបីជាទិន្នន័យ ដែលប្រមូលបានក្នុងកំឡុងឆ្នាំ២០២២ មានរួមបញ្ចូលទិន្នន័យអំពីកម្លាំងធ្វើនេសាទជាថ្ងៃធ្វើនេសាទក៏ដោយ ការប្រមូលទិន្នន័យមិនរាប់បញ្ចូលការប៉ាន់ប្រមាណអំពីមេគុណសកម្មភាពនេសាទ (FAC) ដែលជាធម្មតាត្រូវគេប្រើសម្រាប់ការប៉ាន់ប្រមាណផលនេសាទសរុប។ លើសពីនេះទៀត ចំនួនថ្ងៃធ្វើនេសាទតាមការឡើងផលនេសាទនីមួយៗមានភាពមិនស៊ីសង្វាក់គ្នា ដែលធ្វើឱ្យពិបាកក្នុងការគណនាការប៉ាន់ប្រមាណ ដែលអាចទុកចិត្តបានសម្រាប់ផលនេសាទប្រចាំថ្ងៃនិងកម្លាំងធ្វើនេសាទសរុប។ គេរំពឹងថានឹងមានការធ្វើអោយចំនុចនេះ ល្អប្រសើរឡើងបន្ថែមទៀតសម្រាប់ ការអនុវត្តនៅឆ្នាំ២០២៣។

ដូច្នេះ វិធីសាស្ត្រគណនាអនុវត្តដូចគ្នានឹងការគណនានៅឆ្នាំ២០២១ ដោយសារទិន្នន័យ អាចអោយធ្វើការប៉ាន់ប្រមាណផលនេសាទសរុបប្រចាំខែ ដោយផ្អែកលើទម្ងន់ ដែលបានរាយការណ៍ជាមធ្យម និងតាមចំនួនដំណើរនេសាទ ដែលបានរាយការណ៍ (តារាងទី៩)។ ដើម្បីធ្វើអោយមានភាពតំណាងដល់ធាតុផ្សំសំខាន់ៗនៃអួនអូសដល់ផលផល ការប៉ាន់ប្រមាណបានបែងចែកតាមចំណាត់ថ្នាក់ទំហំទូកនេសាទ ដែលប្រើឧបករណ៍អួនអូស ដោយសារវាប៉ះពាល់ដល់ទាំងទម្ងន់ផលនេសាទ និងចំនួននៃដំណើរនេសាទ។

**តារាងទី៩.** ការប៉ាន់ប្រមាណផលនេសាទជាមធ្យមប្រចាំខែតាមថ្នាក់ទូកនេសាទ-ឧបករណ៍ (គ.ក្រ) រួមជាមួយនឹងសូចនាករបង្ហាញពីភាពត្រឹមត្រូវតាមបែបស្ថិតិ

| ថ្នាក់ទូកនេសាទ-ឧបករណ៍ | ទម្ងន់ផលនេសាទមធ្យម (គ.ក្រ) | SD | ចំនួនការឡើងផលនេសាទ | ε% | ដំណើរនេសាទប្រចាំសប្តាហ៍ | ដំណើរនេសាទប្រចាំខែ | ទិន្នផលតាមទូកនេសាទ ប្រចាំខែ (គ.ក្រ) |
|---|---|---|---|---|---|---|---|
| ខ្នាតមធ្យម ១២-១៨ម | ២១៣,០ | ៦៨៧,៤ | ៥៤២ | ១៣,៩% | ៣,៣ | ១៤,៤៩ | ៣០៨៦,៤ |
| ខ្នាតមធ្យម ១៨-២៤ម | ១៧៤៣,៣ | ៤១៤៤,៩ | ៧៨ | ២៦,៩% | | ៥,២១ | ៩០៨២,៣ |
| ខ្នាតតូច < ៦ម | ១៩,២ | ៤,៦ | ៥ | ១០,៧% | ៥ | ២១,៦៥ | ៤១៥,៧ |
| ខ្នាតតូច ៦-១២ម | ៧៨,៤ | ២២១,៤ | ៣៩៥ | ១៤,២% | ៣,៩ | ១៦,៩ | ១៣២៤,៩ |
| អួនអូស ៦-១២ម | ១០៥,៥ | ២៣០,៧ | ៤១១ | ១០,៨% | ៣,៩ | ១៦,៩៥ | ១៧៨៧,៤ |
| អួនអូស ១២-១៨ម | ១០២០,៣ | ២៥៤៧,០ | ៣១៧ | ១៤,០% | ៤,៩ | ២១,១៨ | ២១.៦០៩,៤ |
| អួនអូស ១៨-២៤ម | ១៧៣២,៩ | ៣២៩៤,៣ | ៣៦ | ៣១,៧% | | ១១,៧១ | ២០.២៩២,៦ |

ចំណាំថាការប៉ាន់ប្រមាណអំពីទិន្នផលនេសាទប្រចាំខែសម្រាប់ទូកនេសាទតូចជាង ៦ម៉ែត្រ គឺផ្អែកលើការសង្កេតចំនួនតែ ៥ ប៉ុណ្ណោះ នៅតាមកន្លែងឡើងផលនេសាទ ។ ដោយសារ ការតាមដាន វាយតម្លៃផលនេសាទសមុទ្រ មិនបានអង្កេតទូកនេសាទខ្នាតធំ ការប៉ាន់ប្រមាណនេះ មិនបានបញ្ចូលការរួមចំណែកនៃទូកនេសាទខ្នាតធំឡើយ។ ផលនេសាតប្រចាំខែ និងប្រចាំឆ្នាំ ផ្អែកលើសកម្មភាពនេសាទ ដែលបានប៉ាន់ប្រមាណ (សមាមាត្រនៃទូកនេសាទសកម្មរៀងរាល់ខែ) ដែលគេធ្វើការកំណត់យកកម្រិតសកម្ម ៨៥%។ ការប៉ាន់ប្រមាណផលនេសាទសរុបប្រើប្រាស់ចំនួនទូកនេសាទដូច ដែលបានរួមបញ្ចូលនៅក្នុងមូលដ្ឋានទិន្នន័យទូកនេសាទឆ្នាំ២០១៨ ដើម្បីបូកសរុបផលនេសាទតាមទូកនេសាទជាមធ្យមប្រចាំខែ មានគណនាក្នុងតារាងទី១០។

**តារាងទី១០.** ប៉ាន់ប្រមាណផលនេសាតសរុបប្រចាំខែ និងប្រចាំឆ្នាំ (តោន) តាមថ្នាក់ទូកនេសាទ-ឧបករណ៍

| ថ្នាក់ទូកនេសាទ-ឧបករណ៍ | លេខទូកនេសាទ | ទូកនេសាទសកម្ម (៨៥%) | ទិន្នផលប្រចាំខែ (តោន) | ទិន្នផលប្រចាំឆ្នាំ (តោន) | %សរុប |
|---|---|---|---|---|---|
| ខ្នាតមធ្យម ១២-១៨ម | ១៨១៩ | ១៥៤៦ | ៤៧៧១,៦ | ៥៧ ២៥៩ | ២៤,៦% |
| ខ្នាតមធ្យម ១៨-២៤ម | ១១៥ | ៩៨ | ៨៩០,១ | ១០ ៦៨១ | ៤,៦% |
| ខ្នាតតូច < ៦ម | ៩២៤ | ៧៨៥ | ៣២៦,៣ | ៣ ៩១៦ | ១,៧% |
| ខ្នាតតូច ៦-១២ម | ៣១១៥ | ២៦៤៨ | ៣៥០៨,៤ | ៤២ ១០១ | ១៨,១% |
| អួនអូស ៦-១២ម | ១១២០ | ៩៥២ | ១៧០១,៦ | ២០ ៤២០ | ៨,៨% |
| អួនអូស ១២-១៨ម | ៣៩៩ | ៣៣៩ | ៧៣២៥,៦ | ៨៧ ៩០៧ | ៣៧,៨% |
| អួនអូស ១៨-២៤ម | ៥០ | ៤៣ | ៨៧២,៦ | ១០ ៤៧១ | ៤,៥% |
| **សរុបរួមឆ្នាំ២០២២** | | | | **២៣២.៧៥៥** | |

ថ្នាក់ទូកនេសាទ ត្រូវបានជ្រើសរើសសម្រាប់គណនាការប៉ាន់ប្រមាណផលនេសាទសរុប ដើម្បីបង្កើនភាពជាក់លាក់នៃស្ថិតិ ដោយមានបង្ហាញតាមរយៈកំហុសស្តង់ដារសមស្រប ( ៩% )។ វិធីគណនានេះត្រូវបានធ្វើក្នុងគោលបំណងដើម្បីធ្វើការប៉ាន់ប្រមាណផលនេសាទសរុប មិនមែនដើម្បីចាត់ថ្នាក់ផលផលសមុទ្រឡើងវិញទេ។ ការប៉ាន់ប្រមាណទាំងអស់មាន ៩% តូចជាង ៣០% លើកលែងតែទូកនេសាទខ្នាតមធ្យមប្រវែង ១៨-២៤ ម៉ែត្រ ដែលមាន ៩% តូចជាង ៣១,៧%។ តម្លៃនេះមានកម្រិតខ្ពស់ប៉ុន្តែគេអាចអាចទទួលយកបាន ដោយយោងទៅនឹងទិដ្ឋភាពនៃបម្រែបម្រួលខ្ពស់នៃទម្ងន់ផលនេសាទ ដែលបានរាយការណ៍។

ដូចមានបង្ហាញក្នុងតារាងទី១០ ទូកអួនអូសបានរួមចំណែក ៥១,១% នៃផលនេសាទសរុប ដែលជាការរួមចំណែកខ្ពស់បំផុតសម្រាប់ប្រភេទឧបករណ៍នេសាទតែមួយ ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការនេសាទនេះ។ ការប៉ាន់ប្រមាណផលនេសាទសរុបនៅឆ្នាំ២០២២ គឺស្រដៀងគ្នាទៅនឹងការប៉ាន់ប្រមាណសម្រាប់ឆ្នាំ២០២១ (២២០ ៦៨៥តោន) ប្រសិនបើប្រើសមាមាត្រដូចគ្នានៃចំនួនទូកនេសាទសកម្ម (៨៥%)។ ទោះជាយ៉ាងក្តី ដោយសារការគ្របដណ្តប់នៃការអង្កេតអនុវត្តបានកាន់តែប្រសើរឡើងទាំងពេលវេលា និងទំហំ ការប៉ាន់ប្រមាណសម្រាប់ឆ្នាំ២០២២ ចាត់ទុកថាអាចទុកចិត្តបានច្រើនជាង។

ការប៉ាន់ប្រមាណផលនេសាទសរុបដោយឡែកពីគ្នា តាមខេត្ត ដោយរួមបញ្ចូលគ្នានូវទិន្នន័យឆ្នាំ២០២២ ទាំងអស់មានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ៤។ ដោយសារតែទូកនេសាទឡើងផលនេសាទនៅក្រៅខេត្ត ដែលពួកគេបានកត់ត្រានៅក្នុងមូលដ្ឋានទិន្នន័យរបស់ទូកនេសាទ នាំអោយមានបញ្ហាមួយចំនួនជាមួយនឹងវិធីសាស្រ្តគណនានេះ។ មានករណីខ្លះ ដែលមិនមានការកត់ត្រាថ្នាក់ទូកនេសាទនិងខេត្ត ប៉ុន្តែមានរបាយការណ៍ការឡើងផលនេសាទ ឬផ្ទុយពីនេះ មិនមានទិន្នន័យឡើងផលនេសាទ ប៉ុន្តែមានការកត់ត្រាអំពីទូកនេសាទ (ហើយសន្មតថាទូកនេសាទសកម្ម) នៅក្នុងជំរឿនទូកនេសាទឆ្នាំ២០១៨។ កត្តានេះនាំឱ្យមានប៉ះពាល់ដល់ការប៉ាន់ប្រមាណផលនេសាទសរុប។ ជាលទ្ធផល ដោយសារការប្រែប្រួលខ្ពស់នៃចំនួនផលនេសាទដែលបានរាយការណ៍ ប្រសិនបើធ្វើការគណនាតាមខេត្ត និងយោងចំនួនសរុបតាមខេត្ត តម្លៃមួយចំនួនមិនត្រឹមត្រូវតាមបែបស្ថិតិ បើគណនាដោយដាក់ផលនេសាទបញ្ចូលគ្នា ប្រសិនបើគណនាតាមខេត្ត បរិមាណផលនេសាទ គឺជិត ២៦០.០០០តោន ដែលខ្ពស់ជាងការប៉ាន់ប្រមាណថ្នាក់ជាតិ។

ការប៉ាន់ប្រមាណផលនេសាទសរុបដោយផ្អែកលើទិន្នន័យទទួលបានពី ការតាមដាន វាយតម្លៃផលនេសាទសមុទ្រ នៅឆ្នាំ២០២២ គឺមាន ៨៥,៩% ខ្ពស់ជាងការប៉ាន់ប្រមាណដោយ រដ្ឋបាលជលផលបច្ចុប្បន្ន ដែលមានចំនួន ១២៥.២០០តោន។ ទោះបីជាការប៉ាន់ប្រមាណផ្អែកលើលទ្ធផលពីការតាមដាន វាយតម្លៃផលនេសាទសមុទ្រ មានសុពលភាពតាមបែបស្ថិតិក៏ដោយ មានកត្តាមួយចំនួននាំអោយមានភាពខុសគ្នាជាមួយនឹងទិន្នផលសមុទ្រផ្លូវការរបស់រដ្ឋបាលជលផល៖

- **ការគ្របដណ្តប់តាមរយៈពេល៖** របាយការណ៍ឆ្នាំ២០២២ គឺផ្អែកលើទិន្នន័យអង្កេត ៨ខែ ដោយហេតុថាទិន្នន័យផលនេសាទប្រចាំខែមិនមានបម្រែបម្រួលតាមរដូវកាល ការប៉ាន់ប្រមាណ ដែលបង្ហាញនៅទីនេះត្រូវបានគេរំពឹងថាមានភាពតំណាងសម្រាប់ឆ្នាំ២០២២។ ដោយឡែក បើសិនការអង្កេតអាចប្រមូលទិន្នន័យ បាន១២ខែ ក្នុង១ឆ្នាំ ការប៉ាន់ប្រមាណនៃផលនេសាទសរុបអាចខុសគ្នា។ ការប្រមូលផលពេញមួយឆ្នាំគឺចាំបាច់ដើម្បីវាយតម្លៃផលផល។

- **លេខសំគាល់ទូកនេសាទ៖** ការបូកសរុបនៃផលនេសាទរាយការណ៍ប្រចាំខែតាមថ្នាក់ទូកនេសាទត្រូវបានធ្វើឡើងដោយប្រើចំនួនទូកនេសាទសរុបពីមូលដ្ឋានទិន្នន័យជំរឿនទូកនេសាទ (២០១៨) តាមថ្នាក់ទូកនេសាទនីមួយៗ។ មូលដ្ឋានទិន្នន័យជំរឿនទូកនេសាទកន្លែងផុតទៅជិត ៤ឆ្នាំ កត្តានេះអាចធ្វើអោយចំនួនទូកអួនអូស (និងទូកនេសាទផ្សេងទៀត) ប្រហែលជាមិនត្រឹមត្រូវទៀតទេ។ ការចុះបញ្ជី ការផ្តល់អជ្ញាប័ណ្ណ និងការធ្វើអធិការកិច្ចទូកនេសាទ អាចជួយរួមចំណែកដល់ការធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យជំរឿនទូកនេសាទ។
- **ការផ្ទេរផលនេសាទ៖** ទូកនេសាទមួយចំនួនអាចយកផលនេសាទពីទូកនេសាទជាច្រើនដាក់រួមបញ្ចូលគ្នា (ការផ្ទេរផលនេសាទ) ទោះបីទូកនេសាទទាំងអស់ ដែលធ្វើការអង្កេត បញ្ជាក់ថាផលនេសាទរបស់ពួកគេ ជាផលនេសាទបានពីទូកនេសាទតែមួយក៏ដោយ នេះចាំបាច់ត្រូវផ្ទៀងផ្ទាត់តាមរយៈការត្រួតពិនិត្យនៅសមុទ្រ និងប្រព័ន្ធតាមដានទូកនេសាទ (VMS) ពេលអនាគត់។
- **ភាពសកម្មនៃទូកនេសាទ៖** សមាមាត្រនៃទូកនេសាទ ដែលនឹងនេសាទសកម្មជារៀងរាល់ខែគឺមានភាពខុសប្លែកគ្នាតាមថ្នាក់ទូកនេសាទផ្សេងៗគ្នា (និងឧបករណ៍) ប៉ុន្តែបច្ចុប្បន្នមិនមានការប្រមូលទិន្នន័យទាំងនេះឡើយ ហើយការប៉ាន់ប្រមាណផ្អែកលើការកំណត់យកភាពសកម្មនៃទូកនេសាទជាមធ្យម ៨៥% ដោយខណ្ឌរដ្ឋបាលជលផល។ នៅពេលមានទិន្នន័យ នឹងអាចធ្វើអោយគេធ្វើការគណនាភាពសកម្មនៃទូកនេសាទ សម្រាប់ប្រភេទទូកនេសាទ-ឧបករណ៍សំខាន់ៗ។
- **ការគ្របដណ្តប់** ៖ ទិន្នន័យ ដែលមានមិនទាន់តំណាងអោយជលផលទាំងមូលនៅឡើយ។
  - ការប៉ាន់ប្រមាណមិនគ្រប់ដណ្តប់ជលផលខ្នាតធំឡើយ ទោះបីជាមានការអង្កេតទូកនេសាទខ្នាតធំចំនួន ៥ ក៏ដោយ ការរួមបញ្ចូលទិន្នន័យទាំងនេះក្នុងការប៉ាន់ប្រមាណអាចនឹងធ្វើអោយមានកំណើនខ្ពស់ខ្លាំងដល់ផលនេសាទសរុប។
  - ទូកកន្ទុយវែងខ្នាតតូចមិនទាន់ត្រូវបានបញ្ចូលក្នុងការប្រមូលទិន្នន័យនៅឡើយ ហើយការប្រមូលទិន្នន័យអំពីទូកនេសាទប្រភេទនេះ ចាំបាច់ត្រូវអនុវត្តដាច់ដោយឡែក ដើម្បីកែលម្អការប៉ាន់ប្រមាណសម្រាប់ទូកនេសាទខ្នាតតូច ដែលមានប្រវែង < ៦ម៉ែត្រ។
- **ការប្រមូលទិន្នន័យ** ៖ កន្លងមក ការតាមដាន វាយតម្លៃផលនេសាទសមុទ្រពឹងផ្អែកលើការសម្ភាសជាមួយអ្នកនេសាទ និងម្ចាស់ទូកនេសាទ តាមរយៈនេះគេអាចដាក់បញ្ចូលទិន្នន័យបែបរំលឹកឡើងវិញសម្រាប់ទូកនេសាទខ្នាតតូច និងកំណត់ត្រាផលនេសាទផ្អែកលើពាណិជ្ជករ/ម្ចាស់ទូកនេសាទ សម្រាប់ទូកនេសាទខ្នាតមធ្យមមួយចំនួន (មិនមែនទាំងអស់)។ ភាពជឿជាក់នៃទិន្នន័យ ដែលទទួលបាន តានប្រភពនេះ គឺមិនអាចកំណត់បាន។
  - ប្រភពនៃទិន្នន័យ (រំលឹកឡើងវិញ ឬកំណត់ត្រាដោយពាណិជ្ជករ/ម្ចាស់ទូកនេសាទ) កន្លងមកទាន់បានប្រមូលនៅឡើយ ជាអនុសាសន៍ ទិន្នន័យទាំងនេះត្រូវបានណែនាំដល់ការប្រមូលទិន្នន័យឆ្នាំ២០២៣។
  - កន្លងមកមិនមានការស្ទង់មតិសម្រាប់ធ្វើការផ្ទៀងផ្ទាត់ ដើម្បីធ្វើការប៉ាន់ប្រមាណអំពីភាពត្រឹមត្រូវនៃអង្កេតកន្លងទៅ ការស្ទង់មតិផ្ទៀងផ្ទាត់ត្រូវបានគេគ្រោងអនុវត្ត ក្នុងឆ្នាំ២០២៣ អាចជាការស្ទង់មតិដាច់ដោយឡើយ ឬជាគម្រោងស្រាវជ្រាវ។

ការកែលម្អ ដែលបានចង្អុលបង្ហាញខាងលើនឹងត្រូវបានពិភាក្សា ហើយនៅពេលអនុវត្តអនុសាសន៍ទាំងនេះនឹងធ្វើការប៉ាន់ប្រមាណអំពីផលនេសាទសរុបកាន់តែត្រឹមត្រូវ។

## ២.៦. ស្តុកត្រីជាន់គ្នា ការធ្វើចំណាកស្រុក និងឆ្លងដែនស្តុកត្រីខ្ពស់

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងស្តុកត្រីរបស់អង្គការសហប្រជាជាតិ (UNFSA) នៅថ្ងៃទី ១៨ខែមករា ឆ្នាំ២០២០ ហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងដំណើរការការតម្កល់ឯកសារនេះទៅអង្គការសហប្រជាជាតិ។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS) កំណត់ការស្តុកទុកជាន់គ្នាថាជា "ស្តុកដូចគ្នា ឬស្តុកនៃប្រភេទ ដែលពាក់ព័ន្ធគ្នា កើតមានឡើងទាំងនៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងក្នុងតំបន់ខាងក្រៅនិងនៅជាប់នឹងតំបន់សេដ្ឋកិច្ចពិសេសនោះ" ខណៈ ដែលស្តុកមានការធ្វើចំណាកស្រុកខ្ពស់ បង្ហាញជូនក្នុងឧបសម្ព័ន្ធ១ នៃ UNCLOS ដែលតម្រូវអោយប្រទេសហត្ថលេខីចាត់វិធានការដើម្បីធានាបាននូវការអភិរក្សនិងការគ្រប់គ្រង។ លើសពីនេះ កម្ពុជាបានចូលរួមនៅក្នុងផែនការសកម្មភាពថ្នាក់តំបន់ចំនួនពីរ (RPOA) សម្រាប់ការគ្រប់គ្រងស្តុកត្រីឆ្លងដែន៖ ១) RPOA- សម្រាប់ការគ្រប់គ្រងត្រីប្លាធូ និង ២) RPOA លើត្រីធូណា។ កិច្ចព្រមព្រៀងទាំងពីរត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ ក្នុងនាមប្រទេសជាសមាជិក រួមទាំងប្រទេសកម្ពុជា (SEAFDEC ២០១៥) និងអនុវត្តកាតព្វកិច្ចក្នុងការរាយការណ៍អំពីបរិមាណនៃផលនេសាទ ទាក់ទងនឹងស្តុកត្រីជាន់គ្នា និងស្តុកធ្វើចំណាកស្រុកខ្ពស់។

**តារាងទី១១.** របាយការណ៍ផលនេសាទ និងការប៉ាន់ប្រមាណផលនេសាទសរុប (គីឡូក្រាម) សម្រាប់ប្រភេទដែលរួមបញ្ចូលនៅក្នុង UNFSA និង RPOA

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះភាសាខ្មែរ | កំពត | កោះកុង | ព្រះសីហនុ | សរុប | %សរុប | សរុប (តោន) |
|---|---|---|---|---|---|---|---|---|
| *Rastrelliger brachysoma* | Short mackerel | ត្រីប្លាធូ ឬ ត្រីកាម៉ុងខ្លួនខ្លី | ៣៩០៩ | ៣៦៧៥ | ២៤៩២ | ១០០៧៦ | ១,៥៨% | ៣៦៧៨ |
| *Euthynnus affinis* | Mackerel tuna | ត្រីឈាម | | ៣៥០០ | | ៣៥០០ | ០,៥៥% | ១២៨០ |
| *Scomberomorus commerson* | Narrow-barred Spanish mackerel | ត្រីបេកាខ្មៅ ឬ ត្រីបេកាឆ្នូត | | ៣៣២០ | ១០ | ៣៣៣០ | ០,៥២% | ១២១០ |
| *Thunnus tonggol* | Longtail Tuna | ត្រីប្រម៉ា | | ១៥៣៥ | | ១៥៣៥ | ០,២៤% | ៥៥៩ |
| *Sarda orientalis* | Striped bonito | ត្រីឈាមស | ៥០ | | ៩០០ | ៩៥០ | ០,១៥% | ៣៤៩ |
| *Auxis thazard* | Bullet tuna | ត្រីកាឡាំង | | | ១៣០ | ១៣០ | ០,០២% | ៤៧ |
| **ផលនេសាទរាយការណ៍សរុប** | | | ៣៩៥៩ | ១២០៣០ | ៣៥៣២ | ១៩៥២១ | ៣,០៧% | ៧១២៣ |

យោងតាមទិន្នន័យនៃការតាមដាន វាយតម្លៃផលនេសាទសមុទ្រ ផលនេសាទប្រមាណជា ៣% ជាប្រភេទដែលបានរៀបរាប់នៅក្រោម UNFSA និង RPOA តារាងទី១១។ សមាមាត្រនៃប្រភេទទាំងនេះ ដែលមាននៅក្នុងការតាមដាន វាយតម្លៃផលនេសាទសមុទ្រ អាចត្រូវបានធ្វើការគណនា ដោយប្រើការប៉ាន់ប្រមាណសរុបនៃផលនេសាទសមុទ្រ (ដោយផ្អែកលើទិន្នន័យទទួលបានពី ការតាមដាន វាយតម្លៃផលនេសាទសមុទ្រ ឬទិន្នន័យប៉ាន់ប្រមាណផ្លូវការដោយ FiA)។ ការប៉ាន់ប្រមាណផលនេសាទសរុប ដែលរួមបញ្ចូលក្នុងតារាងទី១១ គឺផ្អែកលើការប៉ាន់ប្រមាណដោយផ្អែកលើទិន្នន័យទទួលបានពីការតាមដាន វាយតម្លៃផលនេសាទសមុទ្រ ។

## ២.៧ ទិន្នន័យសេដ្ឋកិច្ចសង្គម

ការតាមដាន វាយតម្លៃផលនេសាទសមុទ្របានប្រមូលទិន្នន័យតម្លៃនៃប្រតិបត្តិការនេសាទ ដែលជាផ្នែកមួយនៃការអង្កេត។ សេចក្តីសង្ខេបលទ្ធផលមានបង្ហាញជូននៅក្នុងតារាងទី១២។ ការវិភាគស៊ីជម្រៅបន្ថែមទៀតត្រូវបានលើកគម្រោងសម្រាប់ឆ្នាំ២០២៣ ដើម្បីបង្កើតអនុសាសន៍សម្រាប់ការប្រមូលទិន្នន័យនេសាទស្តីពីសេដ្ឋកិច្ច-សង្គម។

**តារាងទី១២.** សូចនាករសេដ្ឋកិច្ច-សង្គម ដែលបានជ្រើសរើស ដោយមានការរួមចំណែកដល់តម្លៃនេសាទ តាមខេត្ត និងប្រភេទទូកនេសាទ

| កោះកុង | ចំនួន នាវិក | តម្លៃផល នេសាទមធ្យម (រៀល) | លំហូរសាច់ ប្រាក់ដុល (រៀល) | ចំណេញ ដុល% | ការរួមចំណែកថ្លៃចំណាយ (%) | | | | |
|---|---|---|---|---|---|---|---|---|---|
| ទូកនេសាទ-ឧបករណ៍ | | | | | ប្រាក់ខែ | ប្រេង ម៉ាស៊ីន | ប្រេងឥន្ទនៈ | ទឹកកក | ផ្សេងៗ |
| **ខ្នាតតូច** | ១,៩ | ៦០៧ ៥០០ | -២៧ ៩៩៣ | -៤,៦% | ៤១,៥% | ០,៨% | ៣៩,១% | ៧,៩% | ១០,៨% |
| ខ្នាតមធ្យម ១២-១៨ | ២,៩ | ៣ ៤៧៨ ៥០០ | ៨៩២ ១៦៩ | ២៥,៦% | ៣០,០% | ០,៦% | ៥៤,៣% | ៦,៩% | ៨,១% |
| ខ្នាតមធ្យម >១៨ | ១២,៦ | ៣៥ ៨២៦ ០០០ | ១៤ ៨៩៦ ០០០ | ៤១,៦% | ៣៧,៧% | ០,៤% | ៥២,២% | ៥,១% | ៤,៥% |
| អួនអូស <១២ | ២,៦ | ៣ ៣៤២ ០០០ | -៧១៣ ៧៣១ | -២១,៤% | ១៩,២% | ០,៦% | ៦៧,៦% | ៦,១% | ៦,៥% |
| អួនអូស >១៨ | ៤,៧ | ៨ ៤៨៦ ៥០០ | -៦ ៨៧៣ ៧៥០ | -៨១,០% | ១២,០% | ០,៧% | ៧៦,៤% | ៥,៣% | ៥,៦% |
| អួនអូស ១២-១៨ | ៣,៨ | ៧ ១១៤ ០០០ | -៤ ០៥៦ ៦៤៦ | -៥៧,០% | ១៦,២% | ០,៦% | ៧៣,៣% | ៥,៦% | ៤,៣% |
| ព្រះសីហនុ | ចំនួន នាវិក | តម្លៃផល នេសាទមធ្យម (រៀល) | លំហូរសាច់ ប្រាក់ដុល (រៀល) | ចំណេញ ដុល% | ការរួមចំណែកថ្លៃចំណាយ (%) | | | | |
| ទូកនេសាទ-ឧបករណ៍ | | | | | ប្រាក់ខែ | ប្រេង ម៉ាស៊ីន | ប្រេងឥន្ទនៈ | ទឹកកក | ផ្សេងៗ |
| **ខ្នាតតូច** | ៥,០ | ៤ ៥៥៨ ០០០ | ១ ៩៥០ ១១៤ | ៤២,៨% | ៦៧,៤% | ០,៤% | ១៩,៤% | ៣,៤% | ៩,៤% |
| ខ្នាតមធ្យម ១២-១៨ | ៤,២ | ៣ ០៣៦ ០០០ | ១ ៥០១ ១៣៥ | ៤៩,៤% | ៦៥,១% | ១,៥% | ២១,៣% | ២,៧% | ៩,៤% |
| ខ្នាតមធ្យម >១៨ | ៤,៧ | ៥ ៨៨៣ ៥០០ | ២ ៥៤៩ ២៣៤ | ៤៣,៣% | ៦៦,២% | ០,៦% | ២៣,៦% | ២,៨% | ៦,៨% |
| អួនអូស <១២ | ២,៦ | ៧០២ ០០០ | -៩៧ ៨០៥ | -១៣,៩% | ៣៥,៣% | ៣,៤% | ៥៣,៧% | ១,៩% | ៥,៨% |
| អួនអូស >១៨ | ៣,៩ | ១ ៦២៦ ០០០ | -៨១៧ ៤៩៥ | -៥០,៣% | ១២,៣% | ៣,១% | ៧៩,១% | ២,៤% | ៣,២% |
| អួនអូស ១២-១៨ | ៣,៩ | ១ ៦៧៣ ០០០ | -៤៥ ២៣៩ | -២,៧% | ១៦,៦% | ៣,២% | ៧៥,៣% | ១,៥% | ៣,៤% |

| កំពត | ចំនួន នាវិក | តម្លៃផល នេសាទមធ្យម (រៀល) | លំហូរសាច់ ប្រាក់ដុល (រៀល) | ចំណេញ ដុល% | ការរួមចំណែកថ្លៃចំណាយ (%) | | | | |
|---|---|---|---|---|---|---|---|---|---|
| ទូកនេសាទ-ឧបករណ៍ | | | | | ប្រាក់ខែ | ប្រេង ម៉ាស៊ីន | ប្រេងឥន្ទនៈ | ទឹកកក | ផ្សេងៗ |
| **ខ្នាតតូច** | ១,៩ | ២២៣,០០០ | ១០៧ ៥៥១ | ៤៨,២% | ៦៧,៦% | ០,៥% | ២០,៩% | ១,៨% | ៩,១% |
| ខ្នាតមធ្យម ១២-១៨ | ២,៨ | ១,៥០៨,៥០០ | ៣១៨ ៦៦៥ | ២១,១% | ៦៣,១% | ០,៧% | ៣៣,៤% | ០,៣% | ២,៤% |
| ខ្នាតមធ្យម >១៨ | ៥,៣ | ៥,៦៣៦,០០០ | -២៨២ ៩២៩ | -៥,០% | ៥៦,៥% | ០,៤% | ២៥,៩% | ៧,០% | ១០,២% |
| អួនអូស <១២ | ២,០ | ៤០៩,០០០ | ៤៥ ០០២ | ១១,០% | ២១,៤% | ២,០% | ៦៨,១% | ៣,០% | ៥,៦% |
| អួនអូស >១៨ | - | - | - | - | - | - | - | - | - |
| អួនអូស ១២-១៨ | ២,០ | ៦៩៩,០០០ | ១៨៤ ០៨១ | ២៦,៣% | ២៤,១% | ២,០% | ៦៥,៦% | ២,៩% | ៥,៤% |
| | | | | | | | | | |
| កែប | | | | | ការរួមចំណែកថ្លៃចំណាយ (%) | | | | |

| **ទូកនេសាទ-ឧបករណ៍** | ចំនួននាវិក | តម្លៃផលនេសាទមធ្យម (រៀល) | លំហូរសាច់ប្រាក់ដុល (រៀល) | ចំណេញដុល% | **ប្រាក់ខែ** | **ប្រេងម៉ាស៊ីន** | **ប្រេងឥន្ធនៈ** | **ទឹកកក** | **ផ្សេងៗ** |
|---|---|---|---|---|---|---|---|---|---|
| **ខ្នាតតូច** | ១,៩ | ២១៤ ០០០ | ៦៨ ៧៥៩ | ៣២,១% | ៥៩,៧% | ៥,៨% | ២៦,០% | ១,៨% | ៦,៧% |
| ខ្នាតមធ្យម ១២-១៨ | ២,៨ | ៤៨៤ ០០០ | ១១៦ ៤៦៦ | ២៤,១% | ៥៦,៤% | ២,២% | ៣៣,៧% | ១,៤% | ៦,៣% |
| ខ្នាតមធ្យម >១៨ | ៣,៨ | ៩៣៤ ៥០០ | ៩៧ ០៨៩ | ១០,៤% | ៤០,៥% | ២,៣% | ៥១,៤% | ១,៤% | ៤,៤% |
| អួនអូស <១២ | ២,៦ | ៤០៩ ០០០ | ១២០ ៣០៥ | ២៩,៤% | ៥៥,៥% | ៦,៤% | ២៨,៧% | ២,០% | ៧,៤% |
| អួនអូស >១៨ | - | - | - | - | - | - | - | - | - |
| អួនអូស ១២-១៨ | ២,៩ | ៧៨៧ ៥០០ | ៤២៧ ១៣២ | ៥៤,២% | ៣៨,២% | ១,១% | ៥១,២% | ២,៣% | ៧,៣% |

លំហូរសាច់ប្រាក់សរុប (GFC) និងប្រាក់ចំណេញដុល (GP%) ត្រូវបានគណនាដោយពិចារណាលើការចំណាយប្រតិបត្តិការនេសាទទាំងអស់ ប៉ុន្តែមិនរាប់បញ្ចូលថ្លៃថែទាំនិងការវិនិយោគដើមទុនក្នុងការទិញឧបករណ៍ និងឧបករណ៍ផ្សេងទៀត។ GFC អវិជ្ជមាន (បង្ហាញដោយអក្សរពណ៌ក្រហម) មានន័យថា ផ្អែកលើទិន្នន័យ ដែលទទួលបាន ប្រតិបត្តិការជាមធ្យមមិនរកប្រាក់ចំណេញទេ ដោយសារការចំណាយ ដែលបានរាយការណ៍គឺខ្ពស់ជាងតម្លៃនៃផលនេសាទ។

ប្រតិបត្តិការនេសាទស្ទើរតែទាំងអស់នៅខេត្តកំពតនិងកែប ទទួលបានផលចំណេញ ខណៈប្រតិបត្តិការនេសាទទាំងអស់នៅខេត្តកោះកុងនិងព្រះសីហនុមិនទទួលបានប្រាក់ចំណេញ។ ប្រាក់បៀវត្សរ៍ និងថ្លៃប្រេងឥន្ធនៈ គឺជាធាតុផ្សំដ៏ធំបំផុតនៃតម្លៃប្រតិបត្តិការនេសាទសម្រាប់គ្រប់ថ្នាក់ទូកនេសាទ-ឧបករណ៍។

# ៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការតាមដាន វាយតម្លៃផលនេសាទសមុទ្រ អនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ ដោយមានការសហការជាមួយមន្ត្រីខណ្ឌជលផលតំបន់ឆ្នេរ បានផ្តល់នូវទិន្នន័យនិងព័ត៌មានដែលមានសារៈសំខាន់ស្តីពីជលផលសមុទ្រ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍគោលនយោបាយ ការវាយតម្លៃ និងការសម្រេចចិត្តកាន់តែប្រសើរក្នុងការគ្រប់គ្រង ហើយមានការកែតម្រូវវិធីសាស្ត្រខ្លះដោយមានការគាំទ្របច្ចេកទេសពី FAO CAPFISH។

១. ការប្រមូលទិន្នន័យសេដ្ឋកិច្ចសង្គមចាំបាច់ត្រូវធ្វើការពិនិត្យឡើងវិញ។ ការប្រមូលទិន្នន័យសេដ្ឋកិច្ចសង្គម គួរជាការអង្កេតប្រចាំត្រីមាសឬប្រចាំឆ្នាំ។ ការផ្លាស់ប្តូរវិធីសាស្ត្រ និងកាការអង្កេត ចាំបាច់ត្រូវផ្អែកលើការវិភាគស៊ីជម្រៅបន្ថែមទៀត និងការពិនិត្យឡើងវិញឱ្យស្របតាមតម្រូវការនៃផែនការគ្រប់គ្រងជលផលសមុទ្រ។

២. ភាពត្រឹមត្រូវនៃទិន្នន័យចាំបាច់ត្រូវកែលម្អ៖

ក. ប្រភពនៃទិន្នន័យចាំបាច់ត្រូវបង្ហាញក្នុងអំឡុងពេលសម្ភាសន៍ ថាតើទិន្នន័យដែលបានផ្តល់គឺទទួលបានពី ១. ការរំលឹកឡើងវិញដោយអ្នកនេសាទឬម្ចាស់ទូកនេសាទ ឬ ២. កត់ត្រាចម្លងពីកំណត់ត្រារបស់ពាណិជ្ជករ/ម្ចាស់ទូកនេសាទ។

ខ. ការអង្កេតផ្ទៀងផ្ទាត់ចាំបាច់ត្រូវយកមកពិចារណាដើម្បីកំណត់ទាំងសមាសភាពប្រភេទ និងផលនេសាទតាមប្រភេទដោយប្រើសំណាករងដែលបានទិញពីអ្នកនេសាទ ឬម្ចាស់ទូកនេសាទសម្រាប់ការឡើងផលនេសាទតាមទូកនេសាទ ឧបករណ៍ ដែលជ្រើសរើសដោយចៃដន្យ។

គ. ការកំណត់លក្ខខណ្ឌសុពលភាពសម្រាប់ជាមូលដ្ឋានអនុវត្តនៅទីវាល រួមមាន ការពិនិត្យឡើងវិញនូវ កម្មវិធី KoBo សម្រាប់អង្កេតផលនេសាទ កម្លាំងធ្វើនេសាទនិងតម្លៃ ដើម្បីកាត់បន្ថយការវាយអក្សរបន្ថែម និងចំនុចមិនរួមបញ្ចូលទាំងឡាយ ដើម្បីសម្រួលដល់ការងារសម្អាតទិន្នន័យ។

៣. ចាំបាច់ត្រូវធ្វើការកែលម្អគ្រប់ជ្រុងជ្រោយសម្រាប់ទូកនេសាទខ្នាតតូច< 6ម៉ែត្រដោយបន្ថែមចំនួនសំណាកចៃដន្យសម្រាប់ទូកនេសាទកន្ទុយវែង ដូចដែលបានណែនាំក្នុងអំឡុងពេលការវាយតម្លៃឆ្នាំ២០២១។

៤. ចាំបាច់ត្រូវពិនិត្យឡើងវិញលើការចាត់ថ្នាក់ឧបករណ៍នេសាទ ដែលប្រើក្នុងកម្មវិធី KoBo

ក. ធ្វើការញែកបំបែកអួនអូសជាប្រភេទរង ឧ. pelagic /fly trawlers and beam trawlers

ខ. ពិនិត្យ និងការតម្រូវការចាត់ថ្នាក់និងឈ្មោះ ជាភាសាខ្មែរនិងអង់គ្លេស ធ្វើបច្ចុប្បន្នភាពបញ្ជី (drop-down list) សម្រាប់ជ្រើសរើសប្រភេទឧបករណ៍ ឈ្មោះដែលប្រើក្នុងកម្មវិធី KoBo។

៥. ធ្វើការពង្រឹងការភ្ជាប់ទំនាក់ទំនងទៅនឹងការកែច្នៃ (ការបោះចោលផលនេសាទ) ទាំងតាមរយៈការកែតម្រូវការអង្កេតតាមដាន វាយតម្លៃផលនេសាទបច្ចុប្បន្ន និងការស្រាវជ្រាវបន្ថែម ជាពិសេសសម្រាប់ត្រីជី ត្រី ផលនេសាទផ្សេងទៀត និងផលនេសាទ ដែលគេបោះចោល។

ក. នៅក្នុងការអង្កេតតាមដាននិងវាយតម្លៃផលនេសាទ ប្រសិនបើត្រីជី ត្រី ផលនេសាទផ្សេងទៀតត្រូវបានរាយការណ៍គួរតែមានការបញ្ជាក់អំពីប្រភេទនិងការប្រើប្រាស់ដែលគេបានប្រើវាសម្រាប់៖ ចំណីត្រី ចំណីសម្រាប់វារីវប្បកម្ម (ចញ្ចឹមក្នុងបែរ) ការប្រើប្រាស់ បរិភោគរបស់មនុស្ស (ស្រស់ឬកែច្នៃ) ចំណីសម្រាប់បសុសត្វ សម្រាប់ធ្វើជីផ្សេងៗទៀត។

